សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Économiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការកែតម្រូវបញ្ជីកំណើត

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ៖ **លោក ជា គួដែន**
**កញ្ញា តាំង សៀវហុង**

ណែនាំដោយ
**លោក គង់ សុភ័ក្រ្ត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការកែតម្រូវបញ្ជីកំណើត

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លោក ជា គូដេន**

**កញ្ញា តាំង សៀវហុង**

ណែនាំដោយ

**លោក គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

## សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឌា គូដែន** និងនាងខ្ញុំ **តាំង សៀវហុង** ជានិសិត្សថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

សូមសម្តែងនូវការគោរពដឹងគុណក្រៃលែង ជូនចំពោះ លោកអ្នកមានគុណទាំងទ្វេរ **លោកឪពុក** និង **អ្នកម្តាយ** ដែលរូបលោកបានផ្តល់កំណើត ប្រឹងប្រែងតស៊ូប្រកបដោយព្រហ្មវិហារធម៌ ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ លះបង់អស់កម្លាំងកាយ កម្លាំងចិត្ត ធនធាន ក្តីស្រឡាញ់ ភាពកក់ក្តៅគ្រប់សព្វបែបយ៉ាង ផ្តល់ឱកាស ឱ្យកូនបានសិក្សារៀនសូត្រ ទទួលបានចំណេះដឹង ដើម្បីឱ្យកូនក្លាយជាពលរដ្ឋល្អក្នុងសង្គម។ មិនត្រឹមតែប៉ុណ្ណោះ លោកឪពុក អ្នកម្តាយតែងតែលើកទឹកចិត្តកូនជានិច្ច អប់រំឱ្យធ្វើសេចក្តីល្អ ប្រកាន់ភ្ជាប់សីលធម៌ គុណធម៌ និងគុណតម្លៃក្នុងការរស់នៅ។

សូមគោរពថ្លែងអំណរគុណ ជូនចំពោះ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងគណៈគ្រប់គ្រង** ទាំងអស់ ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ក្នុងការដឹកនាំគ្រប់គ្រងស្ថាប័នសិក្សាមួយនេះ ដំណើរការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គមជាតិមាតុភូមិ ឱ្យរីកចម្រើនលូតលាស់ជាលំដាប់។ លើសពីនេះទៀត បានជួយណែនាំ បង្ហាត់បង្រៀន សិស្សនិស្សិតទាំងអស់នាពេលកន្លងមក ដែលអាចទទួលបានចំណេះ ជំនាញ ដែលជាប្រយោជន៍ក្នុងការរស់នៅ។

ជាពិសេស សូមគោរពថ្លែងអំណរ អរគុណ ជូនចំពោះ លោកគ្រូ **គង់ សុភ័ក្ត្រ** ដែលលោក ជាគ្រូណែនាំក្នុងដំណើរការតាក់តែងអត្ថបទសារណានេះ ដោយបានណែនាំ ពន្យល់ បង្ហាត់បង្ហាញ ផ្តល់គន្លឹះ តិចនិក ក្នុងការសរសេរអត្ថបទសារណានេះឱ្យបានល្អប្រសើរ។ មិនត្រឹមតែប៉ុណ្ណោះ លោកបានផ្តល់នូវអនុសាសន៍ល្អៗ ក្នុងការកែតម្រូវនូវចំណុចខ្វះខាត នៃការសរសេរអត្ថបទសារណានេះ ដោយបានព្យាយាមឆ្លើយតប រាល់សំណួរ និងចម្ងល់របស់យើងខ្ញុំ ដោយយកចិត្តទុកដាក់ ដើម្បីអាចឱ្យអត្ថបទសារណានេះលេចជារូបរាងឡើង។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីនាក់មានកិត្តិយស សូមលំឱនកាយលើកដៃប្រណម្យបួងសួង គោរពជូនដល់ លោកអ្នកមានគុណទាំងទ្វេ លោកគ្រូ អ្នកគ្រូ សាស្ត្រចារ្យ គណៈគ្រប់គ្រង និងមិត្តភក្តិ ទាំងអស់ ឱ្យជួបប្រទះនឹងភាពសុខដុមរមនា កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងសូមប្រសិទ្ធពរជ័យ ឱ្យជួបប្រទះនឹងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃចន្ទ ទី០៥ ខែសីហា ឆ្នាំ២០២៤*

## **អារម្ភកថា**

ក្នុងនាមយើងខ្ញុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោយពីទទួលបានការបណ្តុះបណ្តាលរយៈពេល ៤ ឆ្នាំកន្លងមក យើងខ្ញុំទទួលបានចំណេះដឹង បទពិសោធយ៉ាងច្រើន ក្នុងការសិក្សាផ្នែកទ្រឹស្តី ក្រោមការបង្ហាត់បង្រៀន ណែនាំ លត់ដំ ដោយយកចិត្តទុកដាក់ ពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ រហូតធ្វើឱ្យយើងខ្ញុំ មានលទ្ធភាព និងទទួលបានឱកាស ក្នុងការសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

តាមរយៈការសិក្សានាពេលកន្លងមក និងការណែនាំអំពីលោកគ្រូដឹកនាំ បូករួមទាំងការសង្កេតឃើញពីបាតុភាពក្នុងសង្គម មានប្រជាពលរដ្ឋជាច្រើននាក់កំពុងតែជួបប្រទះនឹងបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត និងដោយយល់ថាប្រធានបទដែលនឹងស្រាវជ្រាវ ជាបញ្ហាដែលកើតឡើងថ្មីៗផងនោះ ហេតុនេះហើយ យើងខ្ញុំក៏សម្រេចជ្រើសយកប្រធានបទស្តីពី "***ការកែតម្រូវបញ្ជីកំណើត***" ដើម្បីធ្វើការស្រាវជ្រាវ។

ហេតុនេះ យើងខ្ញុំសង្ឃឹមថាស្នាដៃមួយនេះ អាចរួមចំណែកជួយផ្សព្វផ្សាយចំពោះបញ្ហាពាក់ព័ន្ធនឹងការកែតម្រូវទិន្នន័យ និងមោឃភាពដល់មិត្តនិស្សិតដែលបានអានអត្ថបទសារណានេះ។ ម្យ៉ាងទៀត ឯកសារស្រាវជ្រាវមួយនេះនឹងត្រូវបានរក្សាទុកជាស្នាដៃដល់ មិត្តនិស្សិត អ្នកអាន អ្នកសិក្សាជំនាន់ក្រោយទៀត ដើម្បីងាយស្រួលដល់ការស្រាវជ្រាវ និងស្វែងយល់បន្ថែមលើអត្ថបទដែលទាក់ទងនឹងប្រធានបទមួយនេះផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមអភ័យទោស រាល់កំហុសខុសឆ្គងទាំងឡាយដែលកើតឡើងដោយអចេតនាចំពោះខ្លឹមសារ ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឬរាល់ចំណុចខ្វះខាតផ្សេងៗ។ យើងខ្ញុំរីករាយនឹងទទួលនូវការរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលម្អអត្ថបទសារណានេះ ឱ្យកាន់តែមានភាពល្អប្រសើរ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃចន្ទ ទី០៥ ខែសីហា ឆ្នាំ២០២៤*

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ ៣

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១

## មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត


**ផ្នែកទី១ មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយ មន្ត្រីអត្រានុកូលដ្ឋាន** ........ ៥

១.១ មូលហេតុនៃការកែតម្រូវទិន្នន័យ ........ ៥

១.១.១ កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ........ ៥

១.១.២ កំហុសរបស់បុគ្គលដែលប្រើប្រាស់ឯកសារ ........ ៧

១.១.៣ ការទទួលស្គាល់ ........ ៧

១.១.៤ ការប្តូរនាមត្រកូលក្រោយអាពាហ៍ពិពាហ៍ឬក្រោយការលែងលះ ........ ៨

១.២ មូលហេតុនៃការមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ........ ៨

**ផ្នែកទី២ មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើតដោយតុលាការ** ...... ៩

២.១ ករណីក្រៅពីសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ......... ៩

២.២ ករណីពុំខុសទិន្នន័យ តែច្បាប់តម្រូវ ឬផ្តល់សិទ្ធិឱ្យកែតម្រូវ ......... ៩

២.២.១ ការបដិសេធបិតុភាព ......... ៩

២.២.២ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្តិភាព ......... ១០

២.២.៣ ការប្តូរនាមត្រកូលក្រោយពេលបង្កើតស៊ុំកូន ឬក្រោយពេលកាត់កាលនៃកូនស៊ុំ ......... ១០

២.២.៤ ការប្តូរឈ្មោះដោយតុលាការ ......... ១១

## ជំពូកទី២

## នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

**ផ្នែកទី១ វិធីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន** ......... ១៣

១.១. នៅក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន ......... ១៥

១.១.១ ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន ......... ១៥

១.១.២ បែបបទ នីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ក្នុងការកែតម្រូវទិន្នន័យ ......... ១៦

១.១.៣ ការមោឃភាពលើទិន្នន័យដែលមិនអាចកែតម្រូវបាន ......... ១៧

១.១.៤ បែបបទ នីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ក្នុងការមោឃភាព ......... ១៧

១.២ នៅក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន ......... ១៧

១.២.១ ការដាក់ពាក្យសុំ និងទីកន្លែងស្នើសុំ ......... ១៨

១.២.២ ឯកសារភ្ជាប់ពេលដាក់ពាក្យសុំ ......... ១៩

១.២.៣ សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ......... ២០

១.២.៤ រយៈពេលនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ......... ២១

**ផ្នែកទី២ វិធីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយតុលាការ** ........ ២២

២.១. ការដាក់ពាក្យសុំនៅតុលាការ ........ ២៤

២.១.១ របៀបដាក់ពាក្យសុំ ........ ២៤

២.១.២ ការទទួលពាក្យសុំ ........ ២៦

២.១.៣ ការពិនិត្យពាក្យសុំ ........ ២៦

២.២. ការសួរអ្នកដាក់ពាក្យសុំ ឬជនផ្សេងទៀត ........ ២៧

២.៣ ការសម្រេចសេចក្ដី ........ ២៨

## ជំពូកទី ៣

## អានុភាពនៃសេចក្ដីសម្រេច

**ផ្នែកទី១ អានុភាពនៃសេចក្ដីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** ........ ៣០

**ផ្នែកទី២ អានុភាពនៃដីកាសម្រេចរបស់តុលាការ** ........ ៣១

២.១ ក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន ........ ៣១

២.១.១ ការដាក់ពាក្យសុំ និងទីតាំងដាក់ពាក្យសុំ ........ ៣១

២.១.២ ឯកសារភ្ជាប់ពេលដាក់ពាក្យស្នើសុំ ........ ៣២

២.១.៣ ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការនៅរដ្ឋបាលឃុំ សង្កាត់ ........ ៣២

២.២ នៅក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន ........ ៣៣

២.២.១ ការដាក់ពាក្យ និងទីកន្លែងស្នើសុំ ........ ៣៣

២.២.២ ឯកសារភ្ជាប់ពេលដាក់ពាក្យស្នើសុំ ........ ៣៣

២.២.៣ ការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ ........ ៣៣

ក. សមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ........................................................................ ៣៤

ខ. សមត្ថកិច្ចរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម.............................. ៣៤

**សេចក្តីសន្និដ្ឋាន**........................................................................................................ ៣៦

**អនុសាសន៍**................................................................................................................ ៣៨

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្នុងក្របខណ្ឌនៃការអនុវត្តការងារអត្តសញ្ញាណកម្ម ជាពិសេសលើការងារអត្រានុកូលដ្ឋាន កម្ពុជាបានចាប់ផ្តើមពិនិត្យមើលឡើងវិញ នូវភាពមិនច្បាស់លាស់នៃក្របខណ្ឌគតិយុត្ត និងដោះស្រាយចំពោះស្ថានភាពដែល ប្រព័ន្ធគ្រប់គ្រងលើអត្តសញ្ញាណបុគ្គល ត្រូវបានបំផ្លិចបំផ្លាញនៅក្នុងសម័យសង្គ្រាមស៊ីវិល ដោយចាប់ផ្តើមបំពេញទិន្នន័យអត្តសញ្ញាណប្រជាពលរដ្ឋឡើងវិញ ដែលភាគច្រើនផ្អែកទៅលើការចងចាំរបស់បុគ្គលម្នាក់ៗ ដោយគ្មានឯកសារសំអាងជាក់លាក់ឡើយ។

ជាដំណោះស្រាយ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្រានុកូលដ្ឋាន ជាពិសេសអត្រានុកូលដ្ឋានកំណើតបានចាប់ផ្តើមអនុវត្តឡើងវិញនៅទូទាំងប្រទេស រួមទាំងយុទ្ធនាការ នៃការចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅទូទាំងប្រទេស ដែលធ្វើឡើងចាប់ពីខែតុលា ឆ្នាំ២០០៤ ដល់ខែធ្នូ ២០០៦។ ប៉ុន្តែការអនុវត្តរបស់មន្ត្រីអត្រានុកូលដ្ឋាន ដែលមានសមត្ថកិច្ច មានភាពធ្វេសប្រហែស បណ្តាលឱ្យបន្សល់ទុកនូវបញ្ហា កំហុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ខុសពីឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលធ្វើឱ្យមានការលំបាក និងមានភាពស្មុគស្មាញ ដែលទាមទារឱ្យមានការដាក់ចេញគោលការណ៍ ដើម្បីដោះស្រាយជាបន្ទាន់។

យោងតាមស្មារតី នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ការកែតម្រូវទិន្នន័យ ឬការមោឃភាពបញ្ជីអត្រានុកូលដ្ឋានគឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ។ ប៉ុន្តែ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃ ដោយមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាអង្គភាពជំនាញលើការងារអត្រានុកូលដ្ឋាន បានរៀបចំបង្កើត និងដាក់ចេញនូវសេចក្តីណែនាំស្តីពី បែបបទ នីតិវិធីក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ជាពិសេស អត្រានុកូលដ្ឋានកំណើត ដើម្បីផ្តល់សិទ្ធិមួយចំនួនដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិធ្វើការកែតម្រូវ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានបាន ព្រមទាំងចង្អុលបង្ហាញអំពី ការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន នៅពេលមានសេចក្តីសម្រេចរបស់តុលាការពាក់ព័ន្ធនឹងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន។

ទោះបីជា មានការដាក់ចេញនូវសេចក្តីណែនាំ បង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីសម្រួលដល់ ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានក៏ដោយ យើងខ្ញុំសង្កេតឃើញថា ប្រជាពលរដ្ឋនៅតែបង្ហាញនូវក្តីកង្វល់ រអ៊ូរទាំ និងត្អូញត្អែរ ចំពោះការលំបាក និងភាពស្មុគស្មាញនៃនីតិវិធី ក្នុងការផ្តល់សេវាកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដែលមិនទាន់អាចឆ្លើយតបនឹងសំណូមពរ និងតម្រូវការរបស់ពួកគាត់បាន។ ហេតុដូច្នេះហើយ ទើបបានជាយើងខ្ញុំសម្រេច ជ្រើសរើសយកប្រធានបទស្តីពី

*" ការកែតម្រូវបញ្ជីកំណើត "*នេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីភាពពិតនៃបែបបទ នីតិវិធីនៃការកែតម្រូវ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្របតាមស្ថានភាពកម្ពុជាបច្ចុប្បន្ន ការផ្តល់សេវាអត្រានុកូលដ្ឋាន ជាពិសេសចំពោះអត្រានុកូលដ្ឋានកំណើត យើងខ្ញុំសង្កេតឃើញថាមានបញ្ហាឆកល្វែងក្នុងការអនុវត្ត ទាំងអ្នកផ្តល់សេវា និងអ្នកទទួលសេវា ដែលបង្កឱ្យមានបញ្ហាខុសទិន្នន័យក្នុងបញ្ជីកំណើត ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត។ ដូច្នេះបញ្ហាចោទជាចម្បងដែលយើងខ្ញុំនឹងធ្វើការស្រាវជ្រាវគឺ ដើមចមដែលនាំឱ្យមានបញ្ហាខុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ថាតើកើតឡើងក្រោមរូបភាពបែបណា? ហើយបញ្ហាបន្ទាប់នោះគឺ ប្រសិនបើមានបញ្ហាខុសទិន្នន័យក្នុងបញ្ជីកំណើតបែបនេះ តើត្រូវដោះស្រាយដោយរបៀបណា ដើម្បីឱ្យមានភាពត្រឹមត្រូវឡើងវិញ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសង្កេតឃើញពីបាតុភាពក្នុងសង្គម មានប្រជាពលរដ្ឋជាច្រើននាក់កំពុងតែជួបប្រទះនឹងបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀតដែលធ្វើ ឱ្យសាមីខ្លួនជួបការលំបាកយ៉ាងខ្លាំង ក្នុងការស្នើសុំសេវារដ្ឋបាលផ្សេងៗ។ ហេតុនេះហើយយើងខ្ញុំក៏សម្រេចជ្រើសយកប្រធានបទស្តីពី *" ការកែតម្រូវបញ្ជីកំណើត "*ដើម្បីធ្វើការស្រាវជ្រាវក្នុងគោលដៅពិភាក្សាលើបញ្ហាចោទដែលសាធារណៈជនជួបប្រទះនាពេលស្នើសុំសេវាកែតម្រូវទិន្នន័យ ឬ មោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត និងស្វែងយល់អំពីកាតព្វកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន រួមទាំងស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាខុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទស្រាវជ្រាវអំពី ការកែតម្រូវបញ្ជីកំណើតនេះ មានវិសាលភាពគ្របដណ្តប់ទៅលើការផ្តល់សេវាកែតម្រូវទិន្នន័យ និងមោឃភាព បញ្ជីអត្រានុកូលដ្ឋានកំណើតតែប៉ុណ្ណោះ ដោយមិនបានលើកយកការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងមរណៈភាពមកធ្វើការសិក្សាស្រាវជ្រាវនោះទេ ពីព្រោះបញ្ជីអត្រានុកូលដ្ឋានកំណើតចោទជាបញ្ហាខ្លាំងជាងបញ្ជីអត្រានុកូលដ្ឋានពីរផ្សេងទៀត ដោយសារតែកំណើននៃកំណើតប្រជាជនកើនឡើង ដែលធ្វើឱ្យភាគរយបញ្ជីអត្រានុកូលដ្ឋានកំណើតមានបញ្ហាខុសទិន្នន័យមានចំនួនច្រើនជាង។ចំណែកឯ ដែនកំណត់នៃប្រធានបទ គឺផ្តោតលើអំឡុងពេលនៃការចេញសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៤ និងច្បាប់ដែលពាក់ព័ន្ធក្នុងការកែតម្រូវទិន្នន័យ

និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានផ្សេងទៀត។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវប្រធានបទស្តីពី " *ការកែតម្រូវបញ្ជីកំណើត* " អាចជួយលើកកម្ពស់ការយល់ដឹងរបស់សិស្ស និស្សិត និងមិត្តអ្នកអាន ពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន ជាពិសេសបញ្ហាខុសទិន្នន័យនៅក្នុងបញ្ជីអត្រានុកូដ្ឋានកំណើតជាដើម។ តាមរយៈការស្រាវជ្រាវ នឹងចង្អុលបង្ហាញមិត្តអ្នកអាន អំពីការដាក់ពាក្យសុំកែតម្រូវទិន្នន័យក្នុងបញ្ជីកំណើត បែបបទ និងនីតិវិធីនៅក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយស្ថាប័នដែលមានសមត្ថកិច្ច។ ម្យ៉ាងទៀត ក៏អាចចូលរួមចំណែកផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានមួយផ្នែកតូចផងដែរ។ លើសពីនេះទៀត ឯកសារស្រាវជ្រាវនេះអាចជាឯកសារពិគ្រោះ ក្នុងការសិក្សារស្រាវជ្រាវថ្មីៗបន្ថែម ចំពោះប្រធានបទដែលមានលក្ខណៈប្រហាក់ប្រហែល ឬពាក់ព័ន្ធឯទៀត។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងដំណើរការនៃការរៀបចំ ចងក្រង សារណាបញ្ចប់ការសិក្សារ ចំពោះប្រធានបទខាងលើនេះ យើងខ្ញុំប្រើប្រាស់ នូវវិធីសាស្ត្រចំនួនពីរគឺ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ។

ចំពោះវិធីសាស្ត្រ ក្នុងការប្រមូលទិន្នន័យ យើងខ្ញុំមានប្រភពចំនួនពីរទៀតគឺ ប្រភពចម្បង និងប្រភពបន្ទាប់បន្សំ។ ទី១ ប្រភពចម្បង គឺពឹងផ្អែកលើ បទប្បញ្ញាត្តិច្បាប់ ក្រម អនុក្រឹត្យ ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦ យុទ្ធនាការរបស់ក្រសួងយុត្តិធម៌ សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងយុត្តិធម៌ សេចក្តីជូនដំណឹងរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ការបំភ្លឺរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ដែលបន្តអនុវត្ត និងនៅជាធរមាន រួមទាំងសន្និសីទសារព័ត៌មាន កិច្ចប្រជុំ ជាអាទិ៍។ ចំណែកប្រភពទី២ គឺប្រភពន្ទាប់បន្សំ យើងខ្ញុំក៏បានធ្វើការស្ទង់មតិដោយមិនផ្ទាល់តាមប្រព័ន្ធ Google form ក្នុងរង្វង់បញ្ហានៃការកែតម្រូវបញ្ជីអត្រានុកូលដ្ឋានកំណើត និងតាមដាននូវការបញ្ចេញមតិ ការលើកឡើងនូវទស្សនៈនានា ជាសាធារណៈជុំវិញបញ្ហានៃការកែតម្រូវបញ្ជីកំណើត តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម និងកម្មវិធីសេវាកម្មអត្តសញ្ញាណកម្ម GDI eServices ។

ចំណែកឯ វិធីសាស្ត្រក្នុងការវិភាគព័ត៌មាន យើងខ្ញុំបានយកព័ត៌មាន និងទិន្នន័យដែលទទួលបាន ដើម្បីធ្វើការវិភាគ ប្រៀបធៀប ផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែង ដើម្បីរលេចនូវចំណុចល្អប្រសើរ និងចំណុចខ្វះខាតដែលចោទឡើងជាបញ្ហា និងផ្តល់នូវដំណោះស្រាយ ស្របតាមការយល់ឃើញ ដោយផ្អែកលើការពិភាក្សា។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលក្នុងការសិក្សាឈ្វេងយល់លើប្រធានបទស្តីអំពី *"ការកែតម្រូវបញ្ជីកំណើត"* សារណានេះ បានបែងចែកជា ៣ ជំពូកដូចខាងក្រោម៖

ជំពូកទី១ រៀបរាប់អំពីមូលហេតុ និងដើមចមដែលនាំឱ្យមានបញ្ហាខុសទិន្នន័យក្នុងបញ្ជីកំណើត ដែលរួមមាន កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋាន និងកំហុសរបស់សាមីខ្លួនដែលប្រើប្រាស់ឯកសារ។

រីឯជំពូកទី២ បង្ហាញអំពីលំហូបែបបទ នីតិវិធីក្នុងការកែតម្រូវទិន្នន័យ និងមោឃៈភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន និងដោយតុលាការ។

ចំណែកឯ ជំពូកចុងក្រោយ បកស្រាយ អំពីអានុភាពគតិយុត្តនៅពេលសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋាន និងសេចក្តីសម្រេចរបស់តុលាការមានអានុភាពអនុវត្ត។

# ជំពូកទី១
# មូលហេតុនៃការកែតម្រូវទិន្នន័យ
# និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

# ជំពូកទី១

# មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

បញ្ហាខុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងៗទៀត ដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សញ្ញាបត្រ លិខិតឆ្លងដែនជាដើម គឺជាបញ្ហារសើបមួយក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ដែលធ្វើឱ្យរាំងស្ទះ និងមិនអាចប្រើប្រាស់ឯកសារទាំងនោះបាន ជាផ្លូវការ។ ម្លោះហើយ តម្រូវឱ្យមានការកែតម្រូវទិន្នន័យឡើងវិញ ឱ្យស្របជាមួយឯកសារផ្សេងៗទៀតដែលធ្លាប់បានប្រើប្រាស់កន្លងមក។ ប៉ុន្តែ ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត មិនអាចធ្វើបានដោយងាយស្រួលនោះទេ ពីព្រោះមានការព្រួយបារម្ភអំពីការបាត់បង់នូវអត្តសញ្ញាណពិតរបស់បុគ្គលម្នាក់ៗ និងទប់ស្កាត់ការក្លែងបន្លំអត្តសញ្ញាណបុគ្គល ក្នុងគោលដៅឱ្យខ្លួន ទទួលបានផលប្រយោជន៍ ឬរួចផុតពីកាតព្វកិច្ចតាមផ្លូវច្បាប់ជាកំណត់មួយ។

ហេតុនេះ មានភាពចាំបាច់ក្នុងការត្រួតពិនិត្យ ឱ្យបានច្បាស់លាស់ នូវមូលហេតុដែលនាំឱ្យមានការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ហើយនៅក្នុងជំពូកនេះ នឹងលើកឡើងអំពីមូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន (ផ្នែកទី១) និងមូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយរបស់តុលាការ (ផ្នែកទី២)។

## ផ្នែកទី១ មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន

### ១.១ មូលហេតុនៃការកែតម្រូវទិន្នន័យ

មានកត្តាជាច្រើន ដែលបណ្តាលឱ្យ មានបញ្ហាខុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ដែលកត្តាទាំងនោះ អាចស្តែងឡើងក្រោមរូបភាពផ្សេងៗដូចជា កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច (១.១.១) កំហុសរបស់បុគ្គលផ្ទាល់ខ្លួនដែលប្រើប្រាស់ឯកសារ (១.១.២) ករណីដែលច្បាប់កំណត់ជាក់លាក់ ដូចជា ការទទួលស្គាល់(១.១.៣)និងការប្តូរនាមត្រកូលក្រោយអាពាហ៍ពិពាហ៍ឬក្រោយការលែងលះ(១.១.៤) ។

#### ១.១.១ កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច

កំហុសបច្ចេកទេសបស់មន្ត្រីអត្រានុកូលដ្ឋាន សំដៅដល់ទិន្នន័យដែលបានសរសេរខុស ឬភាន់ច្រឡំព័ត៌មាន ឬខកខានមិនបានបំពេញព័ត៌មាន ដោយមន្ត្រីអត្រានុកូលដ្ឋាន។ យោងតាមច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧២៣/

០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ និងសេចក្ដីណែនាំស្ដីពី បែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និមោយភាពបញ្ជីអត្រានុកូលដ្ឋាន លេខ០០៦សណន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤ បានកំណត់ពីកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋាន អាចស្ថិតក្រោមរូបភាពដូចខាងក្រោម៖

ការសរសេរខុសឆ្គងអក្ខរាវិរុទ្ធលើ នាមត្រកូល និង/ឬនាមខ្លួន របស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយជាអក្សរខ្មែរ ឬអក្សរឡាតាំង ។ កំហុសអក្ខរាវិរុទ្ធខាងលើ សំដៅដល់ការសរសេរអក្សរដែលបញ្ចេញសូរសំឡេងដូចគ្នា ឬប្រហាក់ប្រហែលគ្នា ប៉ុន្តែការសរសេរមានលក្ខណៈខុសគ្នា នូវតួអក្សរ ឬព្យញ្ជនៈ ស្របតាមវេយ្យាករណ៍ខ្មែរ។ ជាទឡ្ហីករណ៍ សាមីខ្លួនឈ្មោះ *" សិទ្ធី "* ប៉ុន្តែក្នុងបញ្ជីកំណើតសរសេរ *" សិតធី "* ឬ ឈ្មោះរបស់ឪពុក *"សុខណា"* ប៉ុន្តែក្នុងបញ្ជីកំណើតរបស់សាមីខ្លួនសរសេរ*"សុខនា"* ឬឈ្មោះរបស់ម្ដាយជាអក្សរឡាតាំងក្នុងបញ្ជីកំណើតសរសេរ *" SAMNANG "* ប៉ុន្តែក្នុងបញ្ជីកំណើតរបស់សាមីខ្លួនសរសេរ *" SOMNANG "* ។

ការសរសេរខុសភេទ នៅពេលចុះបញ្ជី ខុសពីឯកសារភ្ជាប់ ដូចជាសាមីខ្លួនជាភេទ *"ប្រុស"* តែក្នុងបញ្ជីកំណើតសរសេរដាក់ថាភេទ *"ស្រី"* ឬសាមីខ្លួនជាភេទ *"ស្រី"* តែក្នុងបញ្ជីកំណើតសរសេរដាក់ថាភេទ *"ប្រុស"*។

ការសរសេរថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយខុសពីឯកសារភ្ជាប់ សំដៅលើការចុះបញ្ជីដោយមានការភាន់ច្រឡំលើខ្ទង់ថ្ងៃ ខែ ឆ្នាំកំណើត ខុសពីឯកសារភ្ជាប់ ដោយសរសេរច្រឡំក្នុងខ្ទង់ថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួន ជាមួយនឹងថ្ងៃ ខែ ឆ្នាំកំណើតរបស់ឪពុក ឬរបស់ម្ដាយ។ ជាក់ស្ដែង នៅក្នុងបញ្ជីកំណើតរបស់សាមីខ្លួនត្រង់ខ្ទង់ថ្ងៃ ខែ ឆ្នាំកំណើតសរសេរច្រឡំដាក់ថា ថ្ងៃទី១០ មករា ២០០០ ប៉ុន្តែថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួនជាក់ស្ដែងគឺ ថ្ងៃទី ០១ មករា ២០០០។

ការសរសេរខុសថ្ងៃ ខែ ឆ្នាំកំណើតតាមប្រតិទិនសុរិយគតិ ដូចជា សរសេរដាក់ថា សាមីខ្លួនកើត នៅថ្ងៃទី ៣០ ខែកុម្ភៈ ឬថ្ងៃទី ៣១ ខែមេសា ដែលជាក់ស្ដែងគ្មានថ្ងៃទី ៣០ ខែកម្ភៈ ឬថ្ងៃទី ៣១ ខែមេសាទេ ក្នុងប្រតិទិនសុរិយគតិ។

ការភាន់ច្រឡំទីតាំងភូមិសាស្ត្ររដ្ឋបាល នៃទីកន្លែងកំណើតរបស់សាមីខ្លួន ឬរបស់ឪពុក ឬរបស់ម្ដាយ។ ឧទាហរណ៍៖ ត្រង់ខ្ទង់ទីកន្លែងកំណើតរបស់ឪពុក នៃបញ្ជីកំណើតរបស់សាមីខ្លួន សរសេរដាក់ថា កើតនៅស្រុកអង្គរបុរីខេត្ត សៀមរាប ប៉ុន្តែជាក់ស្ដែង ស្រុកអង្គរបុរី ស្ថិតនៅក្នុងខេត្តតាកែវ។

ការសរសេរនៅខ្ទង់ទីកន្លែងកំណើត ខុសពីទីកន្លែងកំណើតដែលសាមីខ្លួនបានកើតជាក់ស្ដែង ឬសរសេរខុសទីតាំងភូមិសាស្ត្ររដ្ឋបាលនាសម័យដែលបុគ្គលនោះកើត។ ឧទាហរណ៍៖ បញ្ជីបញ្ជាក់កំណើតរបស់បុគ្គលម្នាក់បានចុះថា កើតនៅឆ្នាំ១៩៨៥ នៅស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ប៉ុន្តែជាក់ស្ដែង ក្នុងអំឡុងឆ្នាំ១៩៨៥ ស្រុកមង្គលបុរី ស្ថិតនៅក្នុងខេត្តបាត់ដំបងនៅឡើយ ពីព្រោះនៅឆ្នាំ១៩៨៥ ពុំទាន់បង្កើតឱ្យមាន ខេត្តបន្ទាយមានជ័យនៅឡើយ។

កំហុសបច្ចេកទេសផ្សេងទៀត ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[1]

ការខកខានមិនបានបំពេញព័ត៌មាននៅក្នុងបញ្ជីអត្រានុកូលដ្ឋាន លើកលែងតែការបន្ថែមទិន្នន័យព័ត៌មានណាដែលធ្វើឱ្យសាមីខ្លួនរួចផុតពីការទទួលខុសត្រូវខាងផ្លូវច្បាប់។[2] ឧទាហរណ៍៖ បញ្ជីបញ្ជាក់កំណើតរបស់បុគ្គលម្នាក់ខកខានមិនបានបំពេញឈ្មោះ ជាអក្សរឡាតាំង ជាដើម។

### **១.១.២ កំហុសរបស់បុគ្គលដែលប្រើប្រាស់ឯកសារ**

ក្រៅពី កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋាន កំហុសមួយចំនួនទៀត កើតឡើងដោយសារប្រជាពលរដ្ឋមួយចំនួន ផ្តល់ព័ត៌មានទិន្នន័យមិនត្រឹមត្រូវ ឬធ្វើការកោសលុប ឬធ្វើការកែតម្រូវ ឬការសរសេរបន្ថែមដោយខ្លួនឯង ដើម្បីបំពេញបំពេញបែបបទផ្សេងៗ ដើម្បីចូលបម្រើការងារ ឬចុះឈ្មោះចូលរៀន ឬដើម្បីបំពេញតម្រូវការណាមួយ ផ្សេងទៀត។[3] ឧទាហរណ៍៖ឪពុក បានកែតម្រូវឈ្មោះរបស់កូនដោយខ្លួនឯង ដែលនៅពេលចុះបញ្ជីសរសេរថា *"ចាន់ថ្លា"* ប៉ុន្តែដោយហេតុគាត់យល់ថាការសរសេរបែបនេះពុំសូវមានអត្ថន័យល្អ គាត់ក៏បានធ្វើការកោសលុបឈ្មោះនោះចេញ ដោយសរសេរជំនួសនូវឈ្មោះថ្មីដែលមានសូរសំឡេងស្រដៀងគ្នា ប៉ុន្តែមានអត្ថន័យល្អប្រសើរជាងមុន ដោយសរសេរថា *"ចន្ទថ្លា"* ។

### **១.១.៣ ការទទួលស្គាល់**

ការទទួលស្គាល់ ជាមធ្យោបាយមួយដើម្បីបង្កើតទំនាក់ទំនងរវាងឪពុក និងកូន ក្នុងករណីដែលមិនអាចសម្រេចអំពីបិតុភាពតាមការសន្មតបាន។ ការទទួលស្គាល់ មិនមែនជាមូលហេតុចម្បងដែលនាំឱ្យធ្វើការកែតម្រូវបញ្ជីកំណើតកូននោះទេ ប៉ុន្តែវាក៏ជាកម្មវត្ថុក្នុងការស្នើសុំទៅមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីចុះឈ្មោះឪពុកដែលបានទទួលស្គាល់កូនទៅក្នុងបញ្ជីកំណើតរបស់កូន។ ក្រមរដ្ឋប្បវេណី កំណត់ការទទួលស្គាល់ មានពីរបែបគឺការទទួលស្គាល់ដោយការស្ម័គ្រចិត្ត និងការទទួលស្គាល់តាមផ្លូវបណ្តឹង។ នៅក្នុងចំណុចនេះ យើងខ្ញុំមិនលើកយកលក្ខខណ្ឌនៃការទទួលស្គាល់ដោយស្ម័គ្រចិត្ត មកបង្ហាញនោះទេ ដោយគ្រាន់តែច្បិចយក ចំណុចដែលពាក់ព័ន្ធនឹងអានុភាពក្រោយរបបនៃការទទួលស្គាល់ដោយស្ម័គ្រចិត្ត បានបង្កើតឡើងប៉ុណ្ណោះ។

កាលណា កូនគ្មានឪពុកតាមផ្លូវច្បាប់ ក្នុងបញ្ជីកំណើតរបស់កូន មន្ត្រីអត្រានុកូលដ្ឋាននឹងមិនបំពេញ

[1] ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣, មាត្រា (ពីពេលនេះតទៅហៅថា ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣) ។

[2] សេចក្តីណែនាំស្តីពីបែបបទ និតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន, លេខ០០៦សណន, ០៧ មីនា ២០២៤ (ពីពេលនេះតទៅហៅថា សេចក្តីណែនាំលេខ០០៦សនណា២០២៤) ។

[3] សេចក្តីបំភ្លឺ, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ០៦ វិច្ឆិកា ២០២៣។

ខ្វង់ព័ត៌មានរបស់ឪពុកនោះទេ ដោយទុកឱ្យនៅទំនេរ។ ប្រសិនបើក្រោយមក មានបុគ្គលណាម្នាក់បានបង្ហាញឆន្ទៈទទួលស្គាល់កូន ហើយបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ ការទទួលស្គាល់អាចធ្វើទៅបានដោយត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលបានចុះបញ្ជីកំណើតរបស់កូននោះ។[4]ម្យ៉ាងទៀត ការទទួលស្គាល់ក៏អាចធ្វើតាមមតកសាសន៍បានដែរ ដោយអ្នកប្រតិបត្តិមតកសាសន៍ត្រូវរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ដែលបានចុះបញ្ជីកំណើតរបស់កូន ដោយភ្ជាប់នឹងឯកសារចម្លងដែល មានសេចក្តីបញ្ជាក់នៃមតកសាសន៍នោះ ក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកប្រតិបត្តិមតកសាសន៍ នោះចូលកាន់កាប់មុខដំណែង។[5]

ក្រោយទទួលបានការរាយការណ៍ពីឪពុក ឬអ្នកប្រតិបត្តិមតកសាសន៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវកែតម្រូវតាមការរាយការណ៍នោះ ហើយដកហូតយកសំបុត្រកំណើតចាស់ និងចេញសំបុត្រកំណើតថ្មី។[6]

### ១.១.៤ ការប្តូរនាមត្រកូលក្រោយអាពាហ៍ពិពាហ៍ឬក្រោយការលែងលះ

ផ្អែកតាមការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[7] ក្រមរដ្ឋប្បវេណី បានផ្តល់សិទ្ធិដល់សហព័ទ្ធ ក្នុងការប្តូរនាមត្រកូលក្រោយពេលរៀបអាពាហ៍ពិពាហ៍បាន ហេតុនេះនាមត្រកូលក្នុងបញ្ជីកំណើតនឹងត្រូវផ្លាស់ប្តូរ។ លើសពីនេះទៀត ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ បានកំណត់អំពីការស្នើសុំប្តូរនាមត្រកូលក្រោយអាពាហ៍ពិពាហ៍ឬក្រោយការលែងលះជាអាទិ៍ ប្រសិនបើបុគ្គលណាស្នើសុំប្តូរនាមត្រកូលរបស់ខ្លួនក្រោយពេលរៀបអាពាហ៍ពិពាហ៍ ឬប្តូរនាមត្រកូលត្រឡប់មកនាមត្រកូលដើមវិញ ក្រោយពេលលែងលះ ឬលុបចោលអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវធ្វើការប្តូរនាមត្រកូល ហើយត្រូវចុះនិទ្ទេសក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើតដោយត្រូវរក្សាទុកទិន្នន័យដើម។[8]

## ១.២ មូលហេតុនៃការមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

ការមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត សំដៅដល់ការបិសេធអានុភាពនៃការចុះបញ្ជីកំណើតចាប់តាំងពីដំបូង រហូតដល់ពេលមានមោឃភាព។ ការធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត អាចជា ការចុះបញ្ជីផ្ទុយពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ការចុះបញ្ជីកំណើតខុសពីបែបបទ នីតិវិធីនៃការងារអត្រា

[4] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៩៧(ចាប់ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[5] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨២ កថាខណ្ឌទី៥។

[6] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨២ កថាខណ្ឌទី៣។

[7] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៥។

[8] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៨។

នុកូលដ្ឋាន ឬការចុះបញ្ជីកំណើតរបស់បុគ្គលម្នាក់លើសពីមួយដងនៅកន្លែងតែមួយ ឬនៅកន្លែងផ្សេងគ្នា។[9] ឧទាហរណ៍៖ ប្រសិនបើមានជនណាម្នាក់រើសបានទារកដែលត្រូវគេបោះបង់ចោល ហើយបានជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ដើម្បីចុះបញ្ជីកំណើតរបស់ទារក ដោយអនុលោមតាមមាត្រា ៣០ (ការចុះបញ្ជីកំណើតរស់សម្រាប់ទារកដែលគេបោះបង់ចោល) នៃច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ ប៉ុន្តែក្រោយមករកឃើញថាទារកនោះ ធ្លាប់ចុះបញ្ជីកំណើតរស់ពីមុនរួចហើយ បញ្ជីកំណើតថ្មីដែលបានធ្វើឡើងក្រោយត្រូវចាត់ទុកជាមោឃៈ ពីព្រោះថា បុគ្គលម្នាក់មិនអាចចុះបញ្ជីកំណើតសើសពី ១ដង បានទេ ដូចនេះមន្ត្រីអត្រានុកូលនឹងដកហូតសំបុត្រកំណើតថ្មី និងសេចក្តីចម្លងសំបុត្រកំណើតថ្មីដែលបានចេញជាលើកទី២។

## ផ្នែកទី២ មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើតដោយតុលាការ

ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតតាមសេចក្តីសម្រេចរបស់តុលាការ សំដៅដល់ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតទាំងឡាយណា ករណីក្រៅពីសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ (២.១) និងករណីពុំខុសទិន្នន័យ តែច្បាប់តម្រូវ ឬផ្តល់សិទ្ធិឱ្យកែតម្រូវ (២.២)។

### ២.១ ករណីក្រៅពីសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

ករណី ក្រៅពីសម្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ គឺសំដៅក្រៅពីចំណុចដែលបានរៀបរាប់ក្នុងផ្នែកទី១( មូលហេតុនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយមន្ត្រីអត្រានុកូលដ្ឋាន) នៃជំពូកទី១។

### ២.២ ករណីពុំខុសទិន្នន័យ តែច្បាប់តម្រូវ ឬផ្តល់សិទ្ធិឱ្យកែតម្រូវ

ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ក្នុងករណីដែលពុំមានខុសទិន្នន័យ ប៉ុន្តែច្បាប់បានតម្រូវឱ្យធ្វើការកែតម្រូវ តាមអានុភាពនៃសេចក្តីសម្រេចរបស់តុលាការ ដោយសារមានការបដិសេធបិតុភាព ឬការបញ្ជាក់អត្ថិភាពនិងនត្ថិភាពនៃចំណងបុត្តភាព ឬរបបសុំកូនត្រូវបានបង្កើតឬត្រូវបានលុបចោល ឬ ករណីខ្លះទៀត ច្បាប់ផ្តល់សិទ្ធិជាកំណត់មួយក្នុងការកែតម្រូវដូចជា ការប្តូរឈ្មោះជាដើម។

#### ២.២.១ ការបដិសេធបិតុភាព

បិតុភាព សំដៅដល់ចំណងគតិយុត្តរវាងឪពុក និងកូន។ ប្រសិនបើ ជនណាម្នាក់ត្រូវបានសន្មតថាជាឪពុក ស្របតាមបញ្ញត្តិមាត្រា ៩៨៨ (ការសន្មតបិតុភាព) នៃក្រមរដ្ឋប្បវេណី ហើយក្រោយមក បានបដិសេធបិតុ

[9] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

ភាពស្របតាមបញ្ញត្តិមាត្រា ៩៨៩ (ការបដិសេធបិតុភាព) នៃក្រមរដ្ឋប្បវេណី នោះអានុភាពនៃការបដិសេធបិតុភាពគឺ ត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន។[10] មានន័យថា ប្រសិនបើជនម្នាក់ត្រូវបានសន្មតជាឪពុក ដូចនេះឈ្មោះរបស់ឪពុកនឹងត្រូវចុះក្នុងបញ្ជីកំណើតរបស់កូន ប៉ុន្តែក្រោយមក ទើបដឹងថាខ្លួនមិនមែនជាឪពុក និងកូនបង្កើត បន្ទាប់មកប្រសិនបើឪពុក ឬកូន បានបដិសេធបិតុភាពវិញ នោះអានុភាពចំពោះបញ្ជីកំណើតរបស់កូន នឹងត្រូវដកឈ្មោះឪពុកចេញ ហេតុនេះ ការបដិសេធបិតុភាព ក៏ជាមូលហេតុនាំឱ្យមានការកែតម្រូវទិន្នន័យដែរ។

### ២.២.២ បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាព

បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព គឺជាបណ្ដឹងទាមទារឱ្យតុលាការបញ្ជាក់អំពីភាពគ្មានទំនាក់ទំនងញាតិលោហិតរវាងឪពុក ឬរវាងម្ដាយ និងកូន។[11] ប្រសិនបើ កូនត្រូវបានចុះបញ្ជីកំណើតថាមានឪពុក និងម្ដាយតាមផ្លូវច្បាប់រួចហើយ ប៉ុន្តែក្រោយមក មានការបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាពរវាងឪពុក ឬ ម្ដាយជាមួយកូន នោះក្នុងបញ្ជីកំណើតរបស់កូនដែលបានចុះឈ្មោះឪពុក ឬម្ដាយពីមុន នឹងក្លាយជាកម្មវត្ថុក្នុងការស្នើសុំកែតម្រូវបញ្ជីកំណើតផងដែរ។

### ២.២.៣ ការប្តូរនាមត្រកូលក្រោយពេលបង្កើតសុំកូន ឬក្រោយពេលកាត់កាលនៃកូនសុំ

ការសុំកូនពេញលេញ សំដៅដល់ការបង្កើតទំនាក់ទំនងញាតិលោហិតរវាងឪពុក ម្ដាយចិញ្ចឹម និងកូនកូនសុំ ហើយក៏ជាការបញ្ចប់ទំនាក់ទំនងញាតិលោហិតរវាងឪពុក ម្ដាយ និងកូនបង្កើតផងដែរ។ប្រសិនបើ ការសុំកូនពេញលេញត្រូវបានបង្កើតឡើង ដោយស្របនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន  អានុភាពនៃសុំកូនពេញលេញគឺកូនសុំ អាចមានសិទ្ធិប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬនាមត្រកូលដែលខ្លួនមានមុនការបង្កើតសុំកូនពេញលេញបាន។[12] ដូចនេះ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្រកំណើត ឬឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ។[13]

ម្យ៉ាងទៀត ការកាត់កាលនៃកូនសុំពេញលេញ អាចធ្វើបានកាលបើ បំពេញលក្ខខណ្ឌក្នុងមាត្រា១០១៦ (ការកាត់កាលនៃកូនសុំពេញលេញ) នៃក្រមរដ្ឋប្បវេណី។ ហើយអានុភាពនៃការកាត់កាលកូនសុំពេញលេញនាំឱ្យញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះដែលត្រូវបាន

[10] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៩២។

[11] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០០២។

[12] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៥ កថាខណ្ឌទី២។

[13] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៨។

បញ្ចប់ ដោយស្មុំកូនពេញលេញត្រូវកើតឡើងវិញ ចាប់ពីថ្ងៃកាត់កាល់។[14]រីឯ កូនស្មុំធម្មតា អាចកាត់កាលបាន បើមានមូលហេតុកំណត់ក្នុងមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល) នៃក្រមរដ្ឋប្បវេណី ហើយអានុភាពនៃការកាត់កាលកូនស្មុំធម្មតា ចំពោះការប្រើប្រាស់នាមត្រកូលគឺ កូនសុំអាចទទួលបានមកវិញនូវនាមត្រកូលមុនស្មុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន។[15]បញ្ហានៅត្រង់ថា ប្រសិនបើ កូនសុំបានប្ដូរនាមត្រកូលដោយយកនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ហើយនៅក្រោយពេលកាត់កាល កូនសុំមានបំណងប្រើនាមត្រកូលដើមវិញ ករណីនេះក៏អាចក្លាយជាកម្មវត្ថុក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើតរបស់កូនស្មុំដែរ។

### ២.២.៤ ការប្ដូរឈ្មោះដោយតុលាការ

ក្នុងករណីដែលឈ្មោះរបស់បុគ្គលណាម្នាក់ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសផ្ទាល់ខ្លួន ផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ឬមានភាពចាំបាច់ពិសេសផ្សេងទៀតក្នុងការប្ដូរ បុគ្គលនោះអាចដាក់ពាក្យសុំប្ដូរឈ្មោះទៅតុលាការដែលមានសមត្ថកិច្ច នៅលំនៅឋានរបស់អ្នកដាក់ពាក្យសុំបាន ដោយបញ្ជាក់មូលហេតុនៃការសុំប្ដូរនោះ។[16] ឈ្មោះដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសផ្ទាល់ខ្លួន ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ល្អ ឬមានភាពចាំបាច់ពិសេសផ្សេងទៀត មិនត្រូវបានកំណត់ច្បាស់ថាជាឈ្មោះបែបណានោះទេ ដោយតម្រូវឱ្យមានការបកស្រាយតាមករណីដែលកើតឡើងជាក់ស្ដែង ដែលអាចជា ឈ្មោះដែលមានអត្ថន័យមិនល្អ មិនសមរម្យ ឬឈ្មោះដែលអាចក្រលាស់ ចេញជាពាក្យអាសអាភាស ជាដើម។

[14] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៧។

[15] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣២ កថាខណ្ឌទី២។

[16] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៩ កថាខណ្ឌទី១។

# ជំពូកទី២
# នីតិវិធីនៃការកែតម្រូវទិន្នន័យ
# និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

# ជំពូកទី២
# នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

ជាការពិតណាស់ការអនុវត្តការងារជាក់ស្តែងឱ្យស្របទៅតាមគោលការណ៍ដែលមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន មិនអាចប្រព្រឹត្តទៅដោយរលូនទេ ហេតុនេះតម្រូវឱ្យមានការធ្វើការកែសម្រួល ឬវិសោធនកម្ម ឬ អាចឈានដល់ការលុបចោលនូវបទប្បញ្ញត្តិចាស់ ឬបង្កើតបទប្បញ្ញត្តិថ្មី ដើម្បីឆ្លើយតបនឹងបញ្ហាចំពោះមុខដែលរារាំងដល់ដំណើរការអនុវត្តច្បាប់ ព្រមទាំងផ្តល់ភាពងាយស្រួល ដល់ប្រជាពលរដ្ឋដែលត្រូវទទួលសេវាសាធារណៈ។ ជាក់ស្តែង អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋានត្រូវបានកែសម្រួលជាបន្តបន្ទាប់ចំនួន ៣ លើកនៅក្នុងឆ្នាំ២០០២ ឆ្នាំ២០០៤ និងឆ្នាំ២០០៥។[17] នៅក្នុងមាត្រា២៥ នៃអនុក្រឹត្យលេខ ១០៣ បានកំណត់អំពីករណីមានការខកខានក្នុងការរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានកំណើតរបស់ទារកហួសរយៈពេល ៣០ ថ្ងៃ តម្រូវឱ្យអ្នកមានកាតព្វកិច្ចរាយករាណ៍ត្រូវសុំសាលក្រមពីតុលាការខេត្ត ក្រុងសាមីជាមុនសិន ទើបមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់អាចចុះក្នុងសៀវភៅអត្រានុកូលដ្ឋានកំណើតបាន។[18] ប៉ុន្តែក្រោយមានការកែសម្រួលតាមរយៈអនុក្រឹត្យ លេខ១៧ បានតម្រូវឱ្យប្តឹងសុំចុះសៀវភៅកំណើតត្រឹម មេឃុំ ឬចៅសង្កាត់តែប៉ុណ្ណោះ។[19] ការកែសម្រួលជាបន្តបន្ទាប់ស្ថិតក្រោមហេតុផលបំពេញបន្ថែមនូវចំណុចខ្វះខាត ការបង្កលក្ខណៈងាយស្រួល និងបង្វិតសេវាសាធារណៈឱ្យដល់មូលដ្ឋានរបស់ប្រជាពលរដ្ឋ។

ទោះជាយ៉ាងនេះក្តី យោងតាមតាមការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យប្រជាពលរដ្ឋ ក្នុងឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ មានប្រជាពលរដ្ឋប្រមាណជិត ៣៥ ភាគរយកំពុងជួបប្រទះបញ្ហាខុសទិន្នន័យអត្តសញ្ញាណរបស់ខ្លួននៅក្នុងបញ្ជី និងសំបុត្រអត្រានុកូលដ្ឋាន ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណដទៃទៀត និងប្រជាពលរដ្ឋខ្លះបានចុះបញ្ជីអត្រានុកូលដ្ឋានប្រភេទតែមួយ លើសពីមួយដង ដែលបានធ្វើឱ្យសាមីខ្លួនជួបផលលំបាកយ៉ាងខ្លាំង ក្នុងការស្នើសុំសេវារដ្ឋបាលផ្សេងៗដូចជា ការចុះឈ្មោះចូលរៀន ការចុះឈ្មោះចូលរួមប្រឡងប្រជែង និងបម្រើការងារជាដើម។[20]

[17] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន, លេខ៦០អនក្រ.បក, ២៤ មិថុនា ២០០២, អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១៧អនក្រ.បក, ១៤ មិថុនា ២០០៤ និងអនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ខ មាត្រា ៥៩ ថ្មីស្ទួន, លេខ១០៦អនក្រ.បក, ២៣ សីហា ២០០៥ (ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ៦០អនក្រ.បក, អនុក្រឹត្យលេខ១៧អនក្រ.បក និងអនុក្រឹត្យលេខ១០៦អនក្រ.បក) ។

[18] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣អនក្រ.បក, ២៩ ធ្នូ ២០០០, មាត្រា២៥(ចាប់ពីពេលនេះតទៅហៅអនុក្រឹត្យលេខ១០៣)។

[19] អនុក្រឹត្យលេខ១៧អនក្រ.បក, មាត្រា២៥ថ្មី។

[20] សេចក្តីណែនាំស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៣៥សណន, ២០ តុលា ២០១៧។

ដើម្បីឆ្លើយតបនឹងផលលំបាកចំពោះមុខ រាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានចេញអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដែលបានផ្តល់ សមត្ថកិច្ចក្នុងការពិនិត្យសម្រេច អនុញ្ញាតឱ្យកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន កំណើតដល់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។[21]

ដោយអនុវត្តតាមស្មារតីអនុក្រឹត្យលេខ១៣៤ ខាងលើនេះ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំស្តីពីការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ក្នុងគោលដៅកាត់បន្ថយភាពស្មុគស្មាញនៃនីតិវិធីកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋាន ជាពិសេសបញ្ជីអត្រានុកូលដ្ឋានកំណើត។ ការស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយសារកំហុសទិន្នន័យត្រូវចែកចេញជា ២ ប្រភេទគឺ ការស្នើសុំកែតម្រូវទិនន្ន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតតាមសំណើរបស់ប្រជាពលរដ្ឋ និងការស្នើសុំកែតម្រូវទិនន្ន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតតាមសេចក្តីសម្រេចរបស់តុលាការ។[22] ដូច្នេះ ក្នុងជំពូកទី២ នេះ នឹងសិក្សាអំពីបែបបទ នីតិវិធីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន (ផ្នែកទី១) និងនីតិវិធីកែតម្រូវទិន្ន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយតុលាការ (ផ្នែកទី២)។

## ផ្នែកទី១ វិធីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ដោយមន្ត្រីអត្រានុកូលដ្ឋាន

ពាក្យថា *"មន្ត្រីអត្រានុកូលដ្ឋាន"* មិនត្រូវបានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយ ផ្តល់និយមន័យជាក់លាក់នោះទេ។ ប៉ុន្តែយើងអាចបំបែកពាក្យនេះជាពីរគឺ ពាក្យថា *"មន្ត្រី"* សំដៅលើអ្នកមានគំនិត អ្នកមានសេចក្តីដឹងការរាក់ជ្រៅ ឬអ្នកប្រឹក្សាការផែនដី។[23] រីឯពាក្យ *" អត្រានុកូលដ្ឋាន"* គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងស្ថានភាពជាក់ស្តែងដែលជននោះមានក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និងដែលបង្កើតឱ្យជននោះមានសិទ្ធិ និងករណីយកិច្ច។[24] ជារួមមន្ត្រីអត្រានុកូលដ្ឋាន សំដៅលើអ្នករាជការសាធារណៈ ឬពលរដ្ឋដែលទទួលអាណត្តិដោយការបោះឆ្នោត ដែលច្បាប់បានប្រគល់សិទ្ធិក្នុងការបំពេញការងារពាក់ពន្ធនឹងការងារអត្តសញ្ញាណកម្ម ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋានជាដើម។ល។

សូមជម្រាបជូនថា មុនឆ្នាំ២០១៧ ខែតុលា រាល់ការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន គឺតុលាការជា

[21] អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, លេខ១៣៤អនក្រ.បក, ០៥ កក្កដា ២០១៦, មាត្រា៥។

[22] សេចក្តីណែនាំលើការអនុវត្តការងារអត្តសញ្ញាណកម្ម, លេខ០០១សណន, ២៧ មីនា ២០២៤។

[23] សម្តេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ។

[24] គណៈកម្មាការជាតិគាំទ្រឃុំ សង្កាត់, *កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន* (ភ្នំពេញ៖ គណៈកម្មាការជាតិគាំទ្រឃុំ សង្កាត់, ២០០៥), ១២។

អ្នកសម្រេច។ ប៉ុន្តែដោយសារប្រជាពលរដ្ឋមានបញ្ហាលំបាកក្នុងការទៅតុលាការ ដូច្នេះ...ក្រសួងមហាផ្ទៃបានសម្រេចបង្កើតនូវមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដែលមុននេះយើងអត់ដែលមានទេ យើងមានតែមន្ត្រីអត្រានុកូលដ្ឋាននៅមូលដ្ឋានឃុំ សង្កាត់ ដែលយើងហៅថាមន្ត្រីអត្រានុកូលដ្ឋាន។...យើងមានការជជែកពិភាក្សាជាមួយក្រសួងយុត្តិធម៌ ដើម្បីបែងចែកការងារណាដែលអាចអនុញ្ញាត ឱ្យក្រសួងមហាផ្ទៃ ដែលមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាសេនាធិការ អាចកែតម្រូវទៅលើទិន្នន័យអត្រានុកូលដ្ឋាននេះបាន។

....

អញ្ចឹងក្រោយពីការពិភាក្សា នៅឆ្នាំ២០១៧ ហ្នឹងគឺ ទិន្នន័យអត្រានុកូលដ្ឋានមួយចំនួនត្រូវបានអនុញ្ញាតឱ្យក្រសួងមហាផ្ទៃ ដែលមានអគ្គនាយដ្ឋានអត្តសញ្ញាណកម្ម ជាសេនាធិការ កែតម្រូវបាន។[25]

ទោះជាយ៉ាងណា ច្បាប់ក៏បានកំណត់នូវបុគ្គលដែលមានលក្ខណៈសម្បត្តិអាចក្លាយជាមន្ត្រីអត្រានុកូលដ្ឋាន រួមមាន ៤ ថ្នាក់គឺ អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ឯអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រីឯអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ចំណែកឯមេឃុំ ចៅសង្កាត់ ក៏ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រងផងដែរ។[26]

បន្ថែមពីនេះ ក៏មានមន្ត្រីអត្រានុកូលដ្ឋានប្រចាំនៅស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស ១ រូប ដែលត្រូវបានចាត់តាំង ដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។[27] យោងតាមច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ ដែលទើបតែដាក់ឱ្យអនុវត្តក្នុងខែកក្កដា ឆ្នាំ២០២៤ថ្មីៗនេះ បានកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ជាពិសេសការផ្តល់សមត្ថកិច្ចក្នុងការពិនិត្យសម្រេច និងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានដល់ មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ហើយមន្ត្រីអត្រានុកូលដ្ឋានផ្សេងទៀតមានតួនាទីត្រឹមតែការកែតម្រូវកំហុសនៅ ក្នុងបញ្ជីអត្រានុកូលដ្ឋានដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតែប៉ុណ្ណោះ។ ដូច្នេះដើម្បីដឹងថា តើពេលណាដែលយើងត្រូវស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើតឬ បញ្ជីបញ្ជាក់កំណើត ត្រឹមមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬស្នើសុំកែតម្រូវដល់មន្ត្រី អត្រានុកូលដ្ឋានថ្នាក់ជាតិ គប្បីសិក្សាឈ្វេងយល់អំពី ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ដែលស្ថិតក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន (១.១) និងនៅក្នុង

[25] ប្រសាសន៍ឯកឧត្តមឧត្តមសេនីយ៍ឯក សាយ ម៉េងឈាង, សន្និសីទសារព័ត៌មានអំពីសមិទ្ធផល ៥ឆ្នាំរបស់ក្រសួងមហាផ្ទៃ, ១៨ តុលា ២០២២ (អាចរកបាននៅ https://www.facebook.com/share/v/jhNUQsyJXGsvonAn/?mibextid=Le6z7H) ។

[26]ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៧-១០។

[27]ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា១១។

ឆ្នាំកន្លងផុត នៃការអនុវត្តការងារអត្រានុកូលដ្ឋាន (១.២) ។

## ១.១. នៅក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន

ចំពោះបែបបទនៃការកែតម្រូវ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ក្នុងនោះក៏មានបញ្ជីអត្រានុកូលដ្ឋានកំណើតផងដែរ ក្រសួងមហាផ្ទៃបានចេញនូវសេចក្ដីណែនាំចំនួន ៣ ជាបន្តបន្ទាប់ដូចជា សេចក្ដីណែនាំស្ដីពីការកែតម្រូវ និងមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋានឆ្នាំ២០១៧ ហើយក្រោយពីអនុវត្ត បានរយៈពេល ២ឆ្នាំ ពោលគឺ នៅឆ្នាំ២០១៩ បានចេញសេចក្ដីណែនាំមួយ ទៀតស្ដីពីការបន្តដំណើរការកែតម្រូវ និងមោឃភាពទិន្នន័យ នៃបញ្ជីអត្រានុកូលដ្ឋាន និងក្រោយមកទៀត ក្នុងឆ្នាំ២០២៤ សេចក្ដីណែនាំមួយផ្សេងទៀតស្ដីពីបែបបទនីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានបានជំនួសឱ្យសេចក្ដីណែនាំឆ្នាំ២០១៩។ ក្នុងចំណោមសេចក្ដីណែនាំទាំងបី មានតែសេក្ដីណែនាំឆ្នាំ ២០២៤ ប៉ុណ្ណោះដែលបានឱ្យនិយមន័យការកែតម្រូវនិងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន នៅក្នុងឆ្នាំកំពុងអនុវត្ត។ ពាក្យ *"នៅក្នុងឆ្នាំកំពុងអនុវត្ត"* សំដៅដល់ការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្នុងឆ្នាំបច្ចុប្បន្ន ដោយគិតពីថ្ងៃទី០១ ខែមករា មកទល់នឹងថ្ងៃទី ៣១ ខែធ្នូ ដោយមិនទាន់ ឆ្លងចូលឆ្នាំថ្មី។ ដូចនេះ ប្រសិនបើមានការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដែលស្ថិតក្នុងឆ្នាំកំពុងអនុវត្ត ច្បាប់បានផ្ដល់សមត្ថកិច្ចក្នុងការកែតម្រូវ និង មោឃភាព ដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ដែលបានចុះបញ្ជីកន្លងមក។[28]

### ១.១.១ ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន

ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបានសំដៅដល់កំហុសទិន្នន័យដែលបានសេសេរខុស ឬភាន់ច្រឡំព័ត៌មាន ឬខកខានមិនបានបំពេញព័ត៌មានដែលជាកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ដូចដែលបានរៀបរាប់ក្នុងចំណុច (១.១.១ កំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់) ផ្នែកទី១ នៃជំពូកទី១ ។ ឧទាហរណ៍ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ ក្រោយពីទារកកើតបានចំនួន១០ថ្ងៃ ឪពុករបស់ទារកបានរាយការណ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ភ្លើងឆេះរទេះ ស្ថិតក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីចុះបញ្ជីកំណើតរបស់ទារក ក្រោយពីមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ភ្លើងឆេះរទេះបានធ្វើនីតិវិធីចប់សព្វគ្រប់ មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ភ្លើងឆេះរទេះ បានចេញសំបុត្រកំណើតរបស់ទារកច្បាប់ដើម ១ច្បាប់ ដល់ឪពុករបស់ទារក ដើម្បីប្រើប្រាស់តាមដែលអាចប្រើបាន។ ប៉ុន្តែក្រោយមកនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៤ ម្ដាយ របស់ទារកបានពិនិត្យឃើញថា សំបុត្រកំណើតរបស់ទារកខុសអក្ខរាវិរុទ្ធត្រង់ឈ្មោះរបស់ទារក ដែលទារកឈ្មោះ *"សាន សីលា"* ប៉ុន្តែមន្ត្រីអត្រានុកូលដ្ឋានបានសរសេរ ដោយភាន់ច្រឡំថា *" សាន សីសា"* ទៅវិញ។

---

[28] សេចក្ដីណែនាំលេខ០០៦សនណ២០២៤ ។

ផ្អែកតាមឧទាហរណ៍ខាងលើនេះ គឺជាករណីដែលអាចដឹងថាទិន្នន័យក្នុងសំបុត្រកំណើតរបស់ទារកខុសអក្ខរាវិរុទ្ធត្រង់ឈ្មោះរបស់ទារក ដោយកំហុសបច្ចេកទេសរបស់មន្ត្រីអត្រានុកូលដ្ឋាន។ ហើយប្រសិនបើមានបំណងចង់កែតម្រូវវិញ ច្បាប់តម្រូវឱ្យ អាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នា អាចដាក់ពាក្យសុំកែតម្រូវទិន្នន័យ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នៃទីតាំងដែលបានចុះបញ្ជីកន្លងមក។ ចំពោះបុគ្គលដែលអាចស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ បានកំណត់រួមមាន សាមីខ្លួននៃបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ឪពុក ម្ដាយ ឬអ្នកអាណាព្យាលបាលសម្រាប់អនីតិជន ក្នុងករណីសុំកែតម្រូវបញ្ជីកំណើត របស់អនីតិជន និងបុគ្គលទាំងឡាយណាដែលមានផលប្រយោជន៍ស្របច្បាប់ក្នុងការកែតម្រូវបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតតាមការកំណត់របស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[29]

សូមបញ្ជាក់ថាការដាក់ពាក្យសុំកែតម្រូវទិន្នន័យក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន ច្បាប់មិនបានកំណត់ច្បាស់លាស់ថា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់នោះទេ។ ម្យ៉ាងទៀត អ្នកដាក់ពាក្យសុំត្រូវតែដាក់ពាក្យសុំកែតម្រូវទិន្នន័យឱ្យបានមុខថ្ងៃឆ្លងចូលឆ្នាំថ្មី ពោលគឺនៅមុនថ្ងៃទី៣១ ខែធ្នូ។ ក្នុងករណីដែលទុកឱ្យឆ្លងចូលឆ្នាំថ្មីនោះ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មិនមានសមត្ថកិច្ចក្នុងការពិនិត្យកែតម្រូវ ឬមោឃភាពទៀតនោះទេ។

### ១.១.២ បែបបទ នីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ក្នុងការកែតម្រូវទិន្នន័យ

ក្រោយពីទទួលបានពាក្យសុំពីសាមីខ្លួន[30] ឬអាណាព្យាបាល ឬញាតិជានីតិជនមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានកំណើត របស់អ្នកដាក់ពាក្យសុំកែតម្រូវទិន្នន័យ ស្របតាមនីតិវិធី ត្រូវឆូតពាក្យដែលសរសេរខុសទាំងនោះដោយ ទឹកប៊ិកពណ៌ក្រហម ដោយរក្សាទុកពាក្យខុសនោះ នៅអាចមើលបាន បន្ទាប់មកសរសេរពាក្យដែលត្រឹមត្រូវ នៅទទឹម ឬនៅពីលើពាក្យដែលខុសទាំងនោះ ដោយទឹកប៊ិកពណ៌ខៀវ រួចសរសេរដោយទឹកប៊ិកពណ៌ក្រហម នៅរឹមទំព័រខាងឆ្វេងថា យល់ព្រមលុបពាក្យដែលសរសេរខុស និងយល់ព្រមសរសេរពាក្យថ្មីជំនួសវិញ។[31]ក្នុងករណីនេះអ្នករាយការណ៍ ឬសាមីខ្លួន ត្រូវផ្តិតស្នាមមេដៃ បន្ទាប់មកមន្ត្រីអត្រានុកូលដ្ឋាននឹងចុះហត្ថលេខា បោះត្រាឈ្មោះ និងចុះកាលបរិច្ឆេទនៃការកែតម្រូវ។[32] ចុងក្រោយមន្ត្រីអត្រានុកូលដ្ឋាននឹងចេញសំបុត្រអត្រានុកូលដ្ឋានកំណើតថ្មី ជូនអ្នករាយការណ៍ ឬសាមីខ្លួន ។ គំរូដែលត្រូវ

[29] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៥។

[30] ក្នុងករណីសាមីខ្លួនជាអ្នកដាក់ពាក្យសុំ គឺសំដៅលើការស្នើរសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋានបញ្ជាក់កំណើត។

[31] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

[32] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

បាននិមិត្តឡើងស្របតាមឧទាហរណ៍នៃចំណុច (១.១.១ ការកែតម្រូវលើកំហុសទិន្នន័យដែលអាចកែតម្រូវបាន) ផ្នែកទី១ នៃជំពូកទី១ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី១)។

### ១.១.៣ ការមោឃភាពលើទិន្នន័យដែលមិនអាចកែតម្រូវបាន

ផ្ទុយពីកំហុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើតដែលអាចកែតម្រូវបាន កំហុសទិន្នន័យដែលបានរៀបរាប់ក្នុង ចំណុច (១.២ មូលហេតុនៃការមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត) ផ្នែកទី១ នៃជំពូកទី១ មិនអាចកែតម្រូវបានទេ។ ដូចនេះបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើតនោះត្រូវទុកជាមោឃៈ ហើយសូមបញ្ជាក់ថា ភាពខុសគ្នារវាងការតម្រូវទិន្នន័យ និងមោឃភាពទិន្នន័យគឺ ការមោឃភាពមានការសរសេរបញ្ជីកំណើត ឬបញ្ជាក់កំណើតនៅសន្លឹកថ្មី តែចុះលេខដដែលដូចនឹងសន្លឹកចាស់ ដែលបានទុកជាមោឃៈ ចំណែកឯ ការកែតម្រូវទិន្នន័យវិញគ្រាន់តែឆូតនូវចំណុចដែលខុស ហើយសរសេរចំណុចត្រឹមត្រូវនៅក្នុងសន្លឹកដដែលនោះ។ ប្រសិនបើមានបញ្ហាដូចក្នុងករណីនេះ សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅជាមួយគ្នា អាចដាក់ពាក្យសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើតបាន នៅទីតាំងឃុំ សង្កាត់ដែលបានចុះបញ្ជីកន្លងមក ដោយមិនទុកឱ្យហួសឆ្នាំកំពុងអនុវត្តនោះឡើយ។

### ១.១.៤ បែបបទ នីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ក្នុងការមោឃភាព

ក្រោយពីទទួលបានពាក្យសុំមោឃភាព ពីសាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅជាមួយគ្នា មន្ត្រីអត្រានុកូលដ្ឋានឃុំសង្កាត់នឹងធ្វើនីតិវិធីដូចតទៅ៖ ទី១ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នឹងសរសេរពាក្យ *"ទុកជាមោឃៈ"*ជាអក្សរធំៗ ដោយទឹកប៊ិកពណ៌ក្រហមនៅចំកណ្តាលបញ្ជីដែលទុកជាមោឃៈនោះ ហើយចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខា ព្រមទាំងបោះត្រារបស់រដ្ឋបាលឃុំ សង្កាត់ ហើយរក្សាទុកជាឯកសារ។ទី២ មន្ត្រីអត្រានុកូលដ្ឋាន មិនហែកបញ្ជីដែលមោឃភាពនោះទេ ហើយបញ្ជីកំណើត ឬបញ្ជាក់កំណើតនៅសន្លឹកបន្ទាប់ ត្រូវយកលេខរៀងដដែល។ ឧទាហរណ៍៖ បញ្ជីលេខ១៨ ទុកជាមោឃៈ ដូច្នេះបញ្ជីនៅសន្លឹកបន្ទាប់ ត្រូវចុះលេខ១៨ ដដែល។ ចុងក្រោយ មន្ត្រីអត្រានុកូលដ្ឋាននឹងសរសេរលើបញ្ជីកំណើត ឬបញ្ជាក់កំណើតនៃសៀវភៅភ្លោះមួយក្បាលទៀត ដោយពាក្យថា *"ដោយសារបញ្ជីអត្រានុកូលដ្ឋានមួយក្បាលទៀតសរសេរខុសមិនអាចកែតម្រូវបានហើយទុកជាមោឃៈ"* (ដូចមាននៅក្នុងឧបសម្ព័ន្ធទី២)។[33]

## ១.២ នៅក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន

ពាក្យថានៅក្នុងឆ្នាំកន្លងផុត ក្នុងន័យនេះ សំដៅដល់ការអនុវត្តការងារអត្រានុកូលដ្ឋានគ្រប់ប្រភេទដែល

[33] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

កន្លងផុត ឬហួសឆ្នាំកំពុងអនុវត្ត ដូចបានរៀបរាប់ក្នុងជំពូកទី២ ផ្នែកទី១ ចំណុច(១.១ នៅក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន) ។

ក្នុងករណីដែលមានកំហុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ប៉ុន្តែមិនបានដាក់ពាក្យសុំកែតម្រូវ និងទុកឱ្យហួសឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន សមត្ថកិច្ចក្នុងការកែតម្រូវ ទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន បានផ្តល់ឱ្យមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។ ការដាក់ពាក្យសុំកែតម្រូវ និងមោឃភាពនៅក្នុងឆ្នាំកន្លងផុត នៃការអនុវត្តការងារអត្រានុកូលដ្ឋានមានភាពលំបាកជាងការកែតម្រូវទិន្នន័យ និងមោឃភាពក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន ដោយសារមានការតម្រូវឱ្យមានឯកសារភ្ជាប់ (១.២.១) មួយចំនួនដែលចាំបាច់ជាឯកសារយោងក្នុងការកែតម្រូវ ឬមោឃភាព ហើយការដាក់ពាក្យសុំ ទីកន្លែងស្នើសុំ (១.២.២) ខ្លះនៅឆ្ងាយពីមូលដ្ឋានជីវភាពរស់នៅរបស់អ្នកស្នើសុំ ព្រមទាំងមានរយៈពេលវែងជាង ការកែតម្រូវឬមោឃភាពក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋានទៀតផង។ ម្យ៉ាងទៀត ការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ (១.២.៣) អាចជាការចេញសេចក្តីសម្រេចកែតម្រូវ ឬមោឃភាព ហើយក៏អាចបដិសេធមិនកែតម្រូវ ឬមោឃភាពដែរ។

### ១.២.១ ការដាក់ពាក្យសុំ និងទីកន្លែងស្នើសុំ

អ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ក្នុងឆ្នាំកន្លងផុត នៃការអនុវត្តការងារអត្រានុកូលដ្ឋាន ត្រូវបានកំណត់ដូចនឹងការដាក់ពាក្យសុំក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋានផងដែរ។ ប៉ុន្តែការដាក់ពាក្យសុំក្នុងករណីនេះ តម្រូវឱ្យធ្វើការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដែលមានទម្រង់ដែលកំណត់ដោយក្រសួងមហាផ្ទៃ (ដូចមានក្នុងឧបសម្ព័ន្ធទី៣)។[34]

ចំណែកឯ ទីតាំង នៃការដាក់ពាក្យសុំកែតម្រូវ និងមោឃភាពក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន យើងអាចដាក់ពាក្យ នៅទីតាំងដូចជា នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅ ផ្លូវជាតិលេខ១ ស្ថិតក្នុងភូមិតាង៉ូវ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬអាចដាក់ពាក្យសុំនៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត របស់សាមីខ្លួនបាន និងកំពុងរក្សាទុក។ បន្ទាប់ពីទទួលបានពាក្យស្នើសុំ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំឯកសារពាក់ព័ន្ធ មករដ្ឋបាលរាជធានី ខេត្ត ក្នុងអំឡុងពេលយ៉ាងយូរ ៣ថ្ងៃ នៃថ្ងៃការងារ។

បន្ទាប់មក រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំឯកសារដែលទទួលបានពី រដ្ឋបាលក្រុង ស្រុក ខណ្ឌ មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរ០៣ថ្ងៃ នៃថ្ងៃការ

[34] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

ងារ។[35]ចំពោះពាក្យថាថ្ងៃការងារ សំដៅលើថ្ងៃរដ្ឋធ្វើការ ដោយមិនរាប់បញ្ចូល ថ្ងៃឈប់សម្រាកក្នុងឱកាសពិធីបុណ្យជាតិ និងអន្តរជាតិផ្សេងៗ ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

ដើម្បីមានភាពងាយស្រួលដោយមិនចាំបាច់ចំណាយពេលវេលា និងថវិការក្នុងការធ្វើដំណើរមកដាក់ពាក្យនៅ នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាពិសេសអ្នកដាក់ពាក្យសុំ ដែលមានទីលំនៅ ឆ្ងាយពីទីតាំងរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឬនៅតាមបណ្តាខេត្តជាដើម អាចដាក់ពាក្យសុំនៅតាម រដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃមូលដ្ឋានរបស់ខ្លួនបាន។

### ១.២.២ ឯកសារភ្ជាប់ពេលដាក់ពាក្យសុំ

រាល់ការដាក់ពាក្យសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ត្រូវភ្ជាប់មកជាមួយឯកសារដែលពាក់ព័ន្ធដូចជា៖ ទី១ សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ប៉ុន្តែក្នុងករណីបាត់សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ត្រូវជំនួសដោយ ពាក្យបណ្តឹងនៅ ប៉ុស្តិ៍រដ្ឋបាល ឬពាក្យបណ្តឹងនៅ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ ទី២ បញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតថតចម្លងដែលត្រូវកែតម្រូវ ឬមោឃភាព ដែលបានបញ្ជាក់នីត្យានុកូលកម្មពីអជ្ញាធរមានសមត្ថកិច្ច ដោយអាចស្នើសុំបាននៅសាលាក្រុង ស្រុក ខណ្ឌ ឬនៅនាយកដ្ឋានអត្រានុកូលដ្ឋាន។ទី៣ សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬក៏លិខិតបញ្ជាក់ទីលំនៅ។ ចុងក្រោយគឺ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយសូមភ្ជាប់មកផងដែរ ប្រសិនបើមានឯកសារយោងផ្សេងទៀតដែលមាន ទិន្នន័យត្រឹមត្រូវដូចជា លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬសញ្ញាបត្រ ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សា ជាដើម។ សូមធ្វើការកត់សម្គាល់ថា រាល់ឯកសារភ្ជាប់ដែលត្រូវបានថតចម្លង ត្រូវតែមានបញ្ជាក់នីត្យានុកូលកម្មទាំងអស់ ទើបមានតម្លៃប្រើប្រាស់ជាផ្លូវការ លើកលែងតែសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម និងសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតប៉ុណ្ណោះ ដែលមិនចាំបាច់ មានបញ្ជាក់នីត្យានុកូលកម្ម។

ចំពោះ ប្រជាពលរដ្ឋដែលមានតម្រូវការដាក់ពាក្យសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត គប្បីសាកសួរព័ត៌មានពីអាជ្ញាធរមានសមត្ថកិច្ច នៅមូលដ្ឋានរបស់ខ្លួនដូចជា មេឃុំ ឬចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ឬអភិបាលក្រុង ស្រុក ខណ្ឌដែលជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ឬមន្ត្រីពាក់ព័ន្ធឯទៀត ឱ្យបានច្បាស់នូវឯកសារចាំបាច់ដែលត្រូវភ្ជាប់មកជាមួយ មុនពេលដាក់ពាក្យសុំ នៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

ម្យ៉ាងទៀត យោងតាមសេចក្តីជូនដំណឹងរបស់ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃបាន

[35] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

បង្កើតក្រុមប្រចាំការសេវាអត្តសញ្ញាណកម្ម និងប្រតិកម្មរហ័ស ដែលមានមន្ត្រីប្រចាំការ រង់ចាំឆ្លើយតបរាល់សំណួរ សំណូមពរ មតិយោបល់ និងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការងារផ្តល់សេវាអត្តសញ្ញាណកម្ម ជូនជារៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ តាមរយៈមធ្យោបាយចំនួនពីរ ដូចខាងក្រោមនេះ៖[36]

ទី១ ទូរស័ព្ទវៃឆ្លាត កម្មវិធីសេវាកម្មអត្តសញ្ញាណកម្ម (GDI eServices) ដែលអាចទាញយកតាមរយៈកម្មវិធី App Store និង Google Play ។ កម្មវិធីនេះអនុញ្ញាតឱ្យយើង ទទួលបានព័ត៌មានស្តីពី សេវាអត្តសញ្ញាណកម្ម រួមមាន អត្រានុកូលដ្ឋាន ស្ថិតិប្រជាពលរដ្ឋ អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន អាចប្រកាសផ្សាយឯកសារអត្តសញ្ញាណកម្មដែលបាត់បង់ ឬរើសបាន តាមដានដំណើរការឯកសារបន្ទាប់ពីស្នើសុំ ស្កេនកូដឯកសារអត្តសញ្ញាណកម្ម ស្វែងរកទីតាំងផ្តល់សេវាអត្តសញ្ញាណកម្ម និងជាពិសេសនោះ អាចសួរនាំពីបញ្ហា ឬចម្ងល់ផ្សេងៗ ព្រមទាំងទទួលបានចម្លើយពីមន្ត្រីជំនាញប្រចាំការ។

ទី២ ទូរស័ព្ទប្រចាំការ (Call Center) លេខ ១២៧១ ដោយឥតគិតថ្លៃសេវាគ្រប់ប្រព័ន្ធទូរស័ព្ទ។

### ១.២.៣ សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិដែលមាន នាយកដ្ឋានអត្រានុកូលដ្ឋាន ជាសេនាធិការ ក្នុងការពិនិត្យមើលលើទិដ្ឋភាពច្បាប់ នៃឯកសារពាក់ព័ន្ធ និងមូលហេតុក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ដើម្បីធានាសង្គតិភាពទិន្នន័យអត្តសញ្ញាណបុគ្គលម្នាក់ៗ។ ក្នុងករណីចាំបាច់ នាយកដ្ឋានអត្រានុកូលដ្ឋាន ត្រូវសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីស្រាវជ្រាវបន្ថែមឱ្យបានច្បាស់លាស់ អំពីមូលហេតុនៃការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជាក់កំណើត រួចលើកយោបល់ជូន អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាកម្ម ដែលជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ពិនិត្យសម្រេច កែតម្រូវ ឬមោឃភាព ឬចេញសេចក្តីសម្រេចបដិសេធ ក្នុងការកែតម្រូវ។[37]

ក្នុងករណី មានការសម្រេចកែតម្រូវទិន្នន័យបញ្ជីកំណើត ឬបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិនឹងចេញសេចក្តីសម្រេចស្តីពី ការកែតម្រូវទិន្នន័យបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតនោះ ព្រមទាំងចេញសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ១ ច្បាប់ ដោយចុះកាលបរិច្ឆេទថ្មីទៅតាមពេលវេលាជាក់ស្តែងដែលបានចេញសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត បន្ទាប់មក មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិដកហូត និងមោឃៈនូវសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើមចាស់ រួមទាំងសេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់

[36] សេចក្តីជូនដំណឹង, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ០៣ សីហា ២០២០។

[37] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

កំណើតទាំងអស់ ដែលបានចេញជូនសាមីខ្លួនប្រើប្រាស់កន្លងមក។[38]

ដោយឡែកក្នុងករណីមានការសម្រេចបដិសេធមិនកែតម្រូវ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់ក្នុងការបដិសេធ។តាមស្មារតីនៃសេចក្ដីណែនាំស្ដីពីបែបបទ នីតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន របស់ក្រសួងមហាផ្ទៃឆ្នាំ២០២៤ អានុភាពនៃសេចក្ដីសម្រេចបដិសេធរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ជាការសម្រេចបើកផ្លូវតវ៉ា ដោយបានចង្អុលបង្ហាញឱ្យសាមីខ្លួនដាក់ពាក្យស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាព ទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីសុំដីកាសម្រេច ក្នុងករណីមានសេចក្ដីសម្រេចបដិសេធខាងលើ។ ទោះជាយ៉ាងនេះក៏ដោយ ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ បានបញ្ញត្តិអំពីបណ្ដឹងមិនសុខចិត្តនឹងការចាត់ចែងសេចក្ដីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋាន ដោយអនុញ្ញាតឱ្យបុគ្គលដែលបានស្នើសុំកែតម្រូវបញ្ជីអត្រានុកូលដ្ឋាន ឬសំណើរផ្សេងៗទៀត អាចដាក់ពាក្យបណ្ដឹងមិនសុខចិត្តនឹងការចេញសេចក្ដីសម្រេចបដិសេធរបស់មន្ត្រីអត្រានុកូលដ្ឋានបាន។ បណ្ដឹងមិនសុខចិត្តសំដៅដល់បណ្ដឹងឧបាស្រ័យតាមផ្លូវរដ្ឋបាលរបស់បុគ្គលណាមួយដែលប្ដឹងចំពោះការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់អាជ្ញាធរមានសមត្ថកិច្ច ចំណែកបែបបទ នីតិវិធីនៃការប្ដឹងមិនសុខចិត្តនេះមិនទាន់ត្រូវបានកំណត់ជាក់លាក់នៅឡើយ ដែលត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើសពីនេះទៀតការប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេចខាងលើ មិនរារាំងការប្ដឹងផ្ទាល់ទៅតុលាការឡើយ។[39]

### ១.២.៤ រយៈពេលនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

រាល់ការស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិត្រូវពិនិត្យ និងសម្រេចស្របទៅតាមករណីដូចតទៅ៖ ទី១ ក្នុងករណីពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតដែលបានដាក់នៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានរយៈពេលមិនលើសពី ៣០ថ្ងៃ នៃថ្ងៃការងារ។ ទី២ ក្នុងករណី ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ដែលបានដាក់នៅ នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានរយៈពេលមិនលើសពី ២០ថ្ងៃ នៃថ្ងៃការងារ។ ចុងក្រោយ ករណីមានការស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតដោយមិនមានឯកសារសម្អាងគ្រប់គ្រាន់ ដែលទាមទារការស្រាវជ្រាវបន្ថែម រយៈពេល នៃការសម្រេចលើករណីនីមួយៗ អាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្ដែង។[40]

[38] សេចក្ដីណែនាំលេខ០០៦សនណ២០២៤។

[39] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៩៨។

[40] សេចក្ដីណែនាំលេខ០០៦សនណ២០២៤។

ផ្អែកលើទិដ្ឋភាពច្បាប់ រយៈពេល នៃការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មានរយៈពេល ជាមធ្យមមិនលើសពី១ខែ ប៉ុន្តែ អាចមានរយៈពេលយូរជាងនេះ អាស្រ័យលើ កង្វះខាតឯកសារយោងក្នុងការធ្វើជាភស្តុតាង ដើម្បីកែម្រូវ ឬមោឃភាព។ដូចនេះ ដើម្បីចៀសវាងបញ្ហាប្រឈមលើពេលវាលា អ្នកដាក់ពាក្យសុំ គប្បីរៀបចំឯកសារពាក់ព័ន្ធទៅតាមករណីជាក់ស្តែង ឱ្យបានគ្រប់គ្រាន់ មុនពេលដាក់ពាក្យស្នើសុំ។ប៉ុន្តែករណីនេះ មិនអាចដាក់បន្ទុកលើប្រជាពលរដ្ឋដែលជាអ្នកស្នើសុំសេវាកែតម្រូវ ឬមោឃភាពទាំងស្រុងនោះទេ មន្ត្រីអត្រានុកូលដ្ឋានដែលនៅមូលដ្ឋានប្រជាពលរដ្ឋ ត្រូវបង្កលក្ខណៈងាយស្រួល និងផ្តល់ការប្រឹក្សាយោបល់ ក្នុងករណីមានការស្នើសុំជំនួយពីប្រជាពលរដ្ឋ ដោយមិនត្រូវមានការពាក់ព័ន្ធនឹងផលប្រយោជន៍នោះទេ។

តាមរយៈ ការស្ទង់មតិដោយមិនផ្ទាល់តាមប្រព័ន្ធ Google form ពាក់ព័ន្ធនឹងបញ្ហាការកែតម្រូវបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ចាប់ពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ ចំពោះសាធារណៈជន ជាពិសេស សិស្ស និស្សិតក្នុងចំណោមប្រមាណជាង ៥០នាក់ បានលើកឡើងពីកង្វល់ស្រដៀងៗគ្នាលើរយៈពេលក្នុងការស្នើសុំសេវាកែតម្រូវ និងមោឃភាពទិន្នន័យថា បានចំណាយពេលវេលាយូរ ដែលជាហេតុធ្វើឱ្យមានការខកខានក្នុងការដាក់ពាក្យស្នើសុំសេវារដ្ឋបាលដូចជា ការដាក់ពាក្យចូលបម្រើការងារ ដាក់ពាក្យចូលរួមប្រឡងប្រជែង ឬដាក់ពាក្យចូលរៀនជាដើម និងមានការត្អូញត្អែរ ចំពោះមន្ត្រីខិលខូចមួយចំនួនដែលមានសមត្ថកិច្ចពាក់ព័ន្ធ ទាមទារផលប្រយោជន៍ ជាប្រាក់កាក់ ជាថ្នូរក្នុងការពន្លឿន ជួយសម្រួល និងផ្តល់អាទិភាពក្នុងការកែតម្រូវ។

ប្រសិនបើ មានភាពមិនប្រក្រតីពាក់ព័ន្ធក្នុងការចាត់ចែង ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋាន បុគ្គលដែលបានស្នើសុំ អាចដាក់ពាក្យបណ្តឹងមិនសុខចិត្តទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយករណីនេះ មិនរារាំងការដាក់ពាក្យបណ្តឹងទៅតុលាការផ្ទាល់ឡើយ។[41]

## ផ្នែកទី២ វិធីកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយតុលាការ

យោងតាម ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម បានកំណត់ឱ្យដាក់ពាក្យសុំទៅតុលាការ ក្នុងករណី ការកែតម្រូវទិន្នន័យ ឬមោឃបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ដោយមូលហេតុ ក្រៅពីកំហុសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ដូចមានកំណត់ក្នុងមាត្រា ៨៦ នៃច្បាប់នេះ។[42] ក្រៅពីកំហុសរបស់មន្ត្រីអត្រានុកូលដ្ឋាន អាចជាការសម្រេចបដិសេធមិនកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ឬការស្នើសុំប្តូរឈ្មោះ ក៏ចាត់ទុកជាកម្មវត្ថុ នៃការដាក់ពាក្យទៅតុលាការផងដែរ។

[41] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៩៨។

[42] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៧។

ប្រសិនបើមានពាក្យសុំទៅតុលាការ បទប្បញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវយកមកអនុវត្ត។[43] ប៉ុន្តែបើពិនិត្យមើលស្មារតីមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មានវិសាលភាពក្នុងចំណោមចំណុចស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធនៃច្បាប់នេះតែប៉ុណ្ណោះ។[44] មានន័យថា ដើម្បីអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះបាន លុះត្រាតែ នៅក្នុងតារាងឧបសម្ព័ន្ធមានបញ្ជាក់អំពីចំណុច នោះច្បាស់លាស់។ ប៉ន្តែបើក្រឡេកមើល តារាងឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនបានកំណត់អំពីចំណុច នៃការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឬការប្តូរឈ្មោះដោយតុលាការ នោះឡើយ។ ហេតុនេះ ការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ឬការប្តូរឈ្មោះ ដោយតុលាការ មិនអាចអនុវត្តតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានឡើយ។ ទោះជាយ៉ាងណា ក៏សង្កេតឃើញមានការអនុវត្ត បានជាហូរហែរកន្លងមក ដោយសារតែការធ្វើបែបនេះ អាចដោះស្រាយបញ្ហាក្នុងសង្គមបាន ម្យ៉ាងទៀត គ្មានបុគ្គលណាម្នាក់ខូចប្រយោជន៍ ផ្ទុយទៅវិញបានផ្តល់ផលប្រយោជន៍ ជាច្រើនដល់ប្រជាជន។

ក្នុងសន្និសីទសារព័ត៌មានស្តីពី ការដាក់ចេញយុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រកតីនៅតាមតុលាការ នៅថ្ងៃទី០៩ ខែមករា ឆ្នាំ ២០២៤ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការជំរុញ និងពន្លឿន ការដោះស្រាយរឿងក្តី នៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យភាពមិនប្រក្រតីនៅតាមតុលាការ បានមានប្រសាសន៍ថា សំណុំរឿងពាក់ព័ន្ធនឹងបញ្ហាអត្រានុកូលដ្ឋាន មានប្រមាណជាង៦,០០០ករណី នៅសាលាជម្រះក្តីទូទាំងប្រទេស ដែលស្មើនឹង ២៣ភាគរយ នៃសំណុំរឿងរដ្ឋប្បវេណីសរុប។ ហើយជាដំណោះស្រាយ ក្រសួងយុត្តិធម៌បានស្នើសុំឱ្យសាលាជម្រះក្តីទូទាំងប្រទេស រៀបចំបង្កើតឱ្យមានចៅក្រមទទួលបន្ទុកលើរឿងក្តីអត្រានុកូលដ្ឋាន និងស្នើសុំក្នុងការអនុវត្តបញ្ហាខាងលើនេះ គឺធ្វើយ៉ាងណាឱ្យបានលឿន និងត្រឹមត្រូវ។ ហើយប្រសិនបើមានបញ្ហាមិនប្រក្រតីណាមួយដូចជា ទុករឿងឱ្យយឺត ឬក៏មានករណីទាមទារ ផលប្រយោជន៍ផ្សេងទៀត ដែលច្បាប់មិនតម្រូវ សុំប្តឹងមកកាន់លេខាធិការដ្ឋាន នៃគណៈបញ្ជាការដឹកនាំយុទ្ធនាការ ដែលជាយន្តការទទួលពាក្យបណ្តឹង។

ក្រោយពីក្រសួងយុត្តិធម៌បានដាក់ចេញនូវយុទ្ធនាការចំនួនពីរខាងលើ រយៈពេល ៦ខែកន្លងមក ដោយគិត

---

[43] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

[44] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមដែលមិនមែនជាបណ្តឹង,នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា៣ (ចាប់ពីពេលនេះតទៅហៅថាច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង)។

ចាប់ពីថ្ងៃទី០៩ ខែមករា ដល់ថ្ងៃ០៩ ខែកក្កដា ឆ្នាំ២០២៤ អ្នកនាំពាក្យក្រសួងយុត្តិធម៌បានចេញសេចក្ដីប្រកាសព័ត៌មាន ស្ដីពីលទ្ធផលនៃការអនុវត្តយុទ្ធនាការនេះ ចំពោះរឿងសំណុំរឿងអាទិភាពទាំង ៤ ដែលរួមមាន៖ សំណុំរឿងចរាចរណ៍ សំណុំរឿងគ្រឿងញៀន សំណុំរឿងក្មេងទំនើង និងសំណុំរឿងអត្រានុកូលដ្ឋានផងដែរ។ ចំពោះសំណុំរឿងអត្រានុកូលដ្ឋាន ត្រូវបែងចែកជាពីរគឺ ទី១ សំណុំរឿងដែលនៅសល់មុនពេលប្រកាស បើកយុទ្ធនាការមានចំនួន ៤៩៨៣ សំណុំរឿង ត្រូវបានដោះស្រាយចប់សព្វគ្រប់ ១០០ ភាគរយ តាំងពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០២៤ ដែលមានរយៈពេលហ័ស ប្រមាណជាង ៣ ខែប៉ុណ្ណោះ បន្ទាប់ពីដាក់ចេញនូវយុទ្ធនាការ។ ទី២ សំណុំរឿងអត្រានុកូលដ្ឋាន ដែលចូលថ្មីមានចំនួន ២១ ៨៣៥ សំណុំរឿង ត្រូវបានតុលាការដោះស្រាយចប់សព្វគ្រប់បានចំនួន១៩ ៧៩៨ សំណុំរឿង ស្មើនឹង៩០ភាគរយ នៃសំណុំរឿងសរុប។[45] តាមរយៈនេះ ឃើញថាបញ្ហាខុសទិន្នន័យក្នុងបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ដែលតម្រូវឱ្យដាក់ពាក្យសុំកែតម្រូវនៅតុលាការ មានចំនួនច្រើនគួរឱ្យកត់សម្គាល់។

ដូចនេះ ដើម្បីអាចដឹងអំពីកាតព្វកិច្ចតុលការ នៅក្នុងផ្នែកនេះនឹងចង្អុលបង្ហាញអំពីដំណើការនីតិវិធីរបស់តុលាការ ក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ដែលរួមមាន ៣ ដំណាក់កាល គឺការដាក់ពាក្យសុំ (២.១) ការសួរអ្នកដាក់ពាក្យសុំ ឬជនពាក់ព័ន្ធ (២.២) និងការចេញសេចក្ដីសម្រេចរបស់តុលាការ (៣.៣)។

## ២.១. ការដាក់ពាក្យសុំនៅតុលាការ

ដំណាក់កាលដំបូងក្នុងដំណើរការកែម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានគឺត្រូវចាប់ផ្ដើមអំពីការដាក់ពាក្យសុំជាមុនសិន ទើបតុលាការអាចទទួលមកដោះស្រាយបាន។ ពាក្យសុំត្រូវគោរពតាមទម្រង់ដែលបានកំណត់ដោយច្បាប់ ហើយត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ច ទើបអាចតុលាការអាចទទួលយកមកដោះស្រាយ តាមផ្លូវច្បាប់បាន។ ដូច្នេះ ក្នុងចំណុចនេះនឹងបង្ហាញ អំពីរបៀបដាក់ពាក្យសុំ (២.១.១) ការទទួលពាក្យសុំ (២.១.២) និងការពិនិត្យពាក្យសុំ (២.១.៣) ដោយតុលាការ។

### ២.១.១ របៀបដាក់ពាក្យសុំ

ការដាក់ពាក្យសុំ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន។[46]ក្នុងករណី ការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ (ដូចមានក្នុងឧបសម្ព័ន្ធទី៤) នៅក្នុងលិខិត នៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចសំខាន់ៗ ដូចខាងក្រោម៖

[45] សេចក្ដីប្រកាសព័ត៌មានស្ដីពីលទ្ធផលរយៈពេល ៦ខែ នៃយុទ្ធនាការជំរុញនិងពន្លឿនរឿងក្ដីនៅតាមតុលាការនិងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ, ក្រសួងយុត្តិធម៌, ១១ កក្កដា ២០២៤ (អាចរកបាននៅ https://www.moj.gov.kh/kh/announcement/321)។

[46] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្ដឹង, មាត្រា២៦។

ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឬប្រសិនបើ មានអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវបញ្ជាក់ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់នោះដែរ។ អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងក្រមរដ្ឋប្បវេណី ចំពោះអនីតិជនអាចជា អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន[47] ចំណែកឯ ជននៅក្រោមអាណាព្យាបាលទូទៅ គឺអ្នកអាណាព្យាបាលទូទៅ។ ឧទាហរណ៍៖ អ្នកដាក់ពាក្យសុំឈ្មោះ សម កុម្ភៈ អាស័យដ្ឋានផ្ទះលេខ២២ ផ្លូវលេខ៣១០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ និងអ្នកតំណាងដែលច្បាប់បានកំណត់ឈ្មោះ សម មករា ជាអ្នកមានអំណាចមេបារបស់ សម កុម្ភៈ អាសយដ្ឋានផ្ទះលេខ២២ ផ្លូវលេខ៣១០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ទី២ ខ្លឹមសារ នៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុចាំបាច់ក្នុងការទាមទារ។ ចំណុច ស្តីពីខ្លឹមសារ នៃដីកាសម្រេច សំដៅលើចំណុចដែលអ្នកដាក់ពាក្យសុំចង់ឱ្យតុលាការសរសេរនៅក្នុងដីកាសម្រេចរបស់ខ្លួន។ឧទាហរណ៍៖ អ្នកដាក់ពាក្យសុំទាមទារឱ្យតុលការកែតម្រូវថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ មកជា ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៤ ដូចនេះប្រសិនបើ តុលាការយល់ថាពាក្យសុំបានធ្វើឡើងត្រឹមត្រូវហើយ តុលាការនឹងទទួលយកពាក្យសុំមកវិនិច្ឆ័យ អំពីការកែតម្រូវថ្ងៃខែឆ្នាំកំណើតនោះ។ រីឯ អង្គហេតុដែលជាមូលហេតុចំបាច់ក្នុងការទាមទារ គឺជាអង្គហេតុដែលបង្ហាញអំពីមូលដ្ឋាន នៃការទាមទាររបស់អ្នកដាក់ពាក្យសុំ។ ឧទាហរណ៍៖ បញ្ជីកំណើតលេខ ០៤ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៥ នៃសៀវភៅកំណើតលេខ ០២/០៤ ត្រង់ចំណុចឆ្នាំកំណើតសាមីខ្លួន មានកំហុសឆ្គងទិន្នន័យជាមួយឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត ដែលពុំអាចប្រើប្រាស់បាន កើតឡើងដោយការធ្វេសប្រហែសរបស់មន្ត្រីអត្រានុកូលដ្ឋាន ពេលចម្លងចូលគល់បញ្ជីខុសពីឯកសារភ្ជាប់។សូមបញ្ជាក់ថា ពាក្យសុំជាលាយលក្ខណ៍អក្សរអាចធ្វើឡើងដោយខ្លួនឯងបាន ឬប្រសិនបើ មិនអាចធ្វើបានទេ អាចពឹងពាក់មន្ត្រីដែលចាំទទួលពាក្យសុំ ឬរកជំនួយពីមេធាវីក៏បាន។

ម្យ៉ាងទៀតអ្នកដាក់ពាក្យសុំត្រូវភ្ជាប់មកជាមួយឯកសារភស្តុតាងដែលខ្លួនមាន និងយល់ថាអាចយកជាសំអាងបាន។ ត្រូវភ្ជាប់មកជាមួយឯកសារដើម ឬឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់ពីអជ្ញាធរមានសមត្ថកិច្ចដែលអាចមានដូចជា សេចក្តីចម្លងសំបុត្រកំណើតដែលត្រូវកែតម្រូវ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់ អត្តសញ្ញាណប័ណ្ណ សញ្ញាបត្រ លិខិតឆ្លងដែន និងលិខិតបញ្ជាក់ការសិក្សារជាដើម។ ហើយក្នុងការអនុវត្តតាមសាលាជម្រះក្តីមួយចំនួន តម្រូវឱ្យមានលិខិតបញ្ជាក់អត្តសញ្ញាណ (ដូចមានក្នុងឧបសម្ព័ន្ធទី៥) ពីមេឃុំ ឬចៅសង្កាត់ផងដែរ។

---

[47] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១៨។

ដោយឡែក ចំពោះការដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍ ចំពោះមុខក្រឡាបញ្ជី នូវចំណុចនីមួយៗ ដូចដែលមានក្នុងលិខិត នៃពាក្យសុំជាលាយលក្ខណ៍អក្សរខាងលើដែរ។ ក្នុងករណីនេះ ក្រឡាបញ្ជីនឹងធ្វើកំណត់ហេតុ ព្រមទាំងចុះហត្ថលេខា ដែលកំណត់ហេតុនោះ ត្រូវចាត់ទុកដូចជាជាលិខិត នៃពាក្យសុំដែរ។[48]

## ២.១.២ ការទទួលពាក្យសុំ

ពាក្យសុំកែតម្រូវ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជាក់កំណើត ត្រូវដាក់នៅសាលដំបូងរាជធានី ខេត្ត ដែលមានសមត្ថកិច្ចផ្តាច់មុខ។ សមត្ថកិច្ចផ្តាច់មុខ មិនមែនភាគីជាអ្នកកំណត់ ហើយក៏មិនអាចអះអាង ដោយតុលាការនោះទេគឺជាសមត្ថកិច្ចដែលត្រូវបានកំណត់ជាក់លាក់ក្នុងបញ្ញត្តិច្បាប់ថាករណីនេះ ឬករណីនោះ បើមានពាក្យសុំ ត្រូវស្ថិតក្រោមសមត្ថកិច្ចផ្តាច់មុខ។[49] ករណីកែតម្រូវបញ្ជីកំណើត ឬបញ្ជាក់កំណើត ពុំមានបទប្បញ្ញត្តិណាមួយកំណត់ច្បាស់លាស់ទេ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងគឺកំណត់យកសាលាដំបូងរាជធានី ខេត្ត នៃទីកន្លែងកំណើតរបស់អ្នកដាក់ពាក្យសុំ។ លេខាធិការដ្ឋាន រដ្ឋបាលសាលាដំបូង ដែលមានសមត្ថកិច្ចជាកន្លែងដែលទទួលពាក្យសុំ ពីអ្នកដាក់ពាក្យស្នើសុំ។

នៅពេលដាក់ពាក្យសុំទៅតុលាការ ច្បាប់កំណត់កាតព្វកិច្ចឱ្យបង់ពន្ធជូនរដ្ឋ។ ហើយចំពោះពាក្យសុំតាមនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដូចជាពាក្យសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាននេះជាដើម ត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន ៥ពាន់រៀល។[50] បន្ថែមពីនេះ ក្រៅពីពន្ធដាក់ពាក្យសុំ តុលាការអាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ ទៅតាមចំនួនដែលតុលាការកំណត់ជាចំនួនទឹកប្រាក់ជាក់លាក់ ដោយយោលលើសកម្មភាពរបស់តុលាការដូចជា ការបញ្ជូនដីកាកោះ ឬឯកសារផ្សេងៗទៅអ្នកដាក់ពាក្យសុំ ព្រមទាំងសកម្មភាពផ្សេងៗទៀត ជាអាទិ៍។[51]

## ២.១.៣ ការពិនិត្យពាក្យសុំ

ក្រោយពី ទទួលបានពាក្យសុំ តុលាការនឹងធ្វើការពិត្យពាក្យសុំ មុននឹងសម្រេចថា ពាក្យសុំតអាចទទួលវិនិច្ឆ័យបាន ឬត្រូវលើកពាក្យសុំនោះចោល។ តុលាការនឹងពិនិត្យមើលលើចំណុចសំខាន់ៗមួយចំនួន ដូចជាការចាត់ចែងរឿងក្តី ទម្រង់នៃពាក្យសុំ និងការបង់ពន្ធ ឬប្រាក់ប្រដាប់ក្តី។ ប្រសិនបើតុលាការពិនិត្យឃើញថា រឿងក្តីណាមួយ មិនស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនទេ អាចផ្ទេររឿងក្តី ទៅតុលាការមានសមត្ថកិច្ច តាមពាក្យសុំរបស់

[48] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២៦។

[49] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៤។

[50] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២២។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦២។

សាមីខ្លួន ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។ [52]

ក្នុងករណី ការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ កាលបើតុលាការពិនិត្យឃើញថា លិខិត នៃពាក្យសុំមិនស្របជាមួយនឹងទម្រង់ ដែលបានកំណត់ក្នុងមាត្រា២៦ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងទេនោះ តុលាការអាចបង្គាប់ឱ្យធ្វើការកែតម្រូវ ដោយកំណត់កំឡុងពេលសមរម្យ។ ប៉ុន្តែបើអ្នកដាក់ពាក្យសុំមិនបានកែតម្រូវក្នុងកំឡុងពេលកំណត់ទេ តុលាការអាចលើកលិខិត នៃពាក្យសុំចោល ដោយដីការសម្រេច។

ចំណែកឯ ការពិនិត្យលើប្រាក់ប្រដាប់ក្តី កាលបើតុលាការពិនិត្យឃើញថា មិនបានបង់ពន្ធដែលច្បាប់បានកំណត់ តុលាការអនុវត្តដូចគ្នានឹងករណីពិនិត្យលើទម្រង់ នៃលិខិតពាក្យសុំដែរ។[53]

## ២.២. ការសួរអ្នកដាក់ពាក្យសុំ ឬជនផ្សេងទៀត

ចំពោះរឿងក្តីទាំងឡាយណា ដែលដំណើការនីតិវិធីតាមនីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ[54] ប៉ុន្តែ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ឬជនផ្សេងទៀត ដែលតុលការយល់ឃើញថាមាភាពចាំបាច់។

ការសួរ ក្នុងន័យនេះគឺជានីតិវិធីដែលអ្នកដាក់ពាក្យសុំ ឬជនពាក់ព័ន្ធផ្សេងទៀត ធ្វើការអះអាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ព្រមទាំងជានីតិវិធីដែលតុលាការប្រមូលព័ត៌មានអំពីនត្ថិភាព ឬអត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ឬជនពាក់ព័ន្ធផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់។

របៀបនៃការសួរ តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ឬជនផ្សេងទៀតដែលតុលាកាយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ។ចំពោះកាលបរិច្ឆេទដើម្បីឱ្យអ្នកដាក់ពាក្យសុំអះអាង តុលាការទទួលស្គាល់ឱ្យសាមីខ្លួនពឹងអ្នកតំណាងដោយអាណត្តិឱ្យបង្ហាញខ្លួនជំនួស ដោយមិនចាំបាច់បង្ហាញខ្លួនចំពោះមុខតុលាការ ដូចនីតិវិធីរដ្ឋប្បវេណីដែរ។

ប៉ុន្តែចំពោះកាលបរិច្ឆេទប្រមូលព័ត៌មានអំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុពីអ្នកដាក់ពាក្យសុំ ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់វិញ តម្រូវឱ្យសាមីខ្លួន ដែលត្រូវបានកោះហៅ បង្ហាញខ្លួនមកតុលាការ និងពន្យល់តុលាការអំពីកាលៈទេសៈ មិនមែនដោយអ្នកតំណាងដោយអាណត្តិ[55]ទេ គឺដោយសាមីអ្នកដាក់ពាក្យសុំ ដើម្បីឱ្យតុលាការក្តោបនូវអង្គហេតុពិតនៅក្នុងរឿងក្តី។ លើលពីនេះ ក្នុងករណី ដែលសាមីខ្លួនត្រូវបង្ហាញខ្លួន អ្នកតំណាងដោយអាណត្តិ ក៏អាចចូលរួមជាមួយសាមីខ្លួនបានដែរ។

[52] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៦។

[53] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២២។

[54] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២៨។

[55] អ្នកតំណាងដោយអាណត្តិក្នុងនីតិវិធីរដ្ឋប្បវេណីសំដៅដល់មេធាវី។

ដោយឡែក ប្រសិនបើជនដែលត្រូវបានតុលាការកោះហៅ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាទឹកប្រាក់មិនលើសពីចំនួន ១លានរៀលបាន។[56]

## ២.៣ ការសម្រេចសេចក្តី

ក្រោយពេល តុលាកាទទួលបានព័ត៌មាន អង្គហេតុពិត ឬភស្តុតាងធនល្មមហើយ តុលាការនឹងចេញដីកាសម្រេចទៅតាមការយល់ឃើញរបស់ខ្លួន និងផ្អែកលើទិដ្ឋភាពច្បាប់។ ដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមដែលបានដំណើការនីតិវិធី ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេច។[57] ដីកាសម្រេចអាចជា ដីកាសម្រេចស្របតាមការទាមទាររបស់អ្នកដាក់ពាក្យសុំ ឬដីកាសម្រេចបដិសេធការទាមទាររបស់អ្នកដាក់ពាក្យសុំ។

បន្ទាប់ពី ចេញដីកាសម្រេច តុលាការត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ឬជនដែលត្រូវទទួលដីកាដោយអាចធ្វើតាមរយៈការបញ្ជូន ឬការផ្ញើជូនឯកសារចម្លងយថាភូតនៃដីកាសម្រេច។[58] ចំណែកវិធីនៃការបញ្ជូនអាចធ្វើឡើង ដោយការផ្ញើតាមរយៈប្រៃសណីយ៍ធម្មតាបាន។

រីឯ អានុភាព នៃដីកាសម្រេចខាងលើ មិនត្រូមានអានុភាពអនុវត្តឡើយ បើមិនទាន់ចូលជាស្ថាពរទេ។[59] ដីកាសម្រេចនឹងចូលជាស្ថាពរ នៅក្រោយផុតអំឡុងពេលសម្រាប់ប្តឹងជំទាស់ ឬក៏ពាក្យបណ្តឹងជំទាស់ត្រូវបានលើកចោលដោយតុលាការ ហើយដីកាដែលចូលជាស្ថាពរនឹងក្លាយជាលិខិតអនុវត្ត។ចំណែកឯ ការធ្វើបណ្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលអ្នកដាក់ពាក្យសុំបានទទួលការជូនដំណឹង អំពីដីកាសម្រេច។[60]

ចំពោះ រយៈពេល នៃការចេញសេចក្តីសម្រេច លើសំណុំរឿងអត្រានុកូលដ្ឋាន ជាពិសេសការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត មិនត្រូវបានកំណត់ជាក់លាក់ដូចទៅនឹងការការកែតម្រូវទិន្នន័យ ឬមោឃភាព ដោយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិនោះទេ ដោយរយៈពេលលឿន ឬយឺតអាស្រ័យលើការចាត់ចែងរឿងក្តីរបស់តុលាការ ពីព្រោះថានៅតាមសាលាជម្រះក្តីភាគច្រើនមានភាពមមាញឹកក្នុងការដោះស្រាយរឿងក្តីផ្សេងៗទៀតដែលកកស្ទះ។ ប៉ុន្តែ តាមរយៈការដាក់ចេញយុទ្ធនាការជំរុញ និងពន្លឿនការដោស្រាយរឿងក្តីនៅតាមតុលាការ សំណុំរឿងអត្រានុកូលដ្ឋានជាសំណុំរឿងអាទិភាពមួយដែលតុលាការ ត្រូវតែសម្រេចឱ្យ

---

[56] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា២៩។

[57] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៣៥។

[58] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៣៦។

[59] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៣៧។

[60] ច្បាប់នីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង, មាត្រា៤០។

បានឆាប់រហ័សតាមដែលអាចធ្វើទៅបាន នៅពេលដែលមានពាក្យសុំទៅតុលាការ។

តាមរយៈប្រសាសន៍របស់ឯកឧត្តម ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ ក្នុងឱកាសនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤ បានបញ្ជាក់ទាក់ទងនឹងបញ្ហានៃការផ្តល់សេវាកែតម្រូវទិន្នន័យពីតុលាការ ក្នុងន័យថា ប្រសិនបើមានឯកសារត្រឹមត្រូវ គឺតុលាការនឹងចេញដីកាសម្រេចនៅថ្ងៃដែលដាក់ពាក្យសុំនោះតែម្តង។ប៉ុន្តែ ក្នុងករណីដែលមិនមានឯកសារគ្រប់គ្រាន់ទេ តុលាការនឹងស្នើសុំអ្នកដាក្យពាក្យសុំ ឱ្យដាក់ឯកសារបន្ថែមជូនតុលាការ បើពុំមានការឆ្លើយតបទេ តុលាការនឹងដាក់តាមនីតិវិធីតាមច្បាប់ យ៉ាងយូរកំណត់អស់ត្រឹម ២ សប្តាហ៍។ ឯកឧត្តមបន្តទៀតថា ករណីដែលមានភាពយឺតយូរ ដោយសារតែបងប្អូនដែលបានស្នើសុំកែតម្រូវ មិនទាន់បានទៅស្វែងរកឯកសារ ឬមិនទាន់បានជួបមេឃុំជាដើម។ គាត់មិនទាន់បានឯកសារមកវិញ ដែលធ្វើឱ្យចំណាយរយៈពេលយូរ គឺក្នុងករណីហ្នឹង។ ឯកឧត្តមបានគូសបញ្ជាក់ជាថ្មីថា អ្នកដែលត្រូវការសេវា កែតម្រូវឈ្មោះ កែតម្រូវអាយុ ឬករណីផ្សេងទៀត ដែលច្បាប់អនុញ្ញាតឱ្យតុលាការធ្វើ គឺមកដល់រងចាំសិន តុលាការពិនិត្យមើលឯកសារគ្រប់គ្រាន់ហើយ គឺចេញជូនភ្លាមតែម្តង អត់មាននីតិវិធីអីយូរទេ។[61]

---

[61] https://vt.tiktok.com/ZS2Ryra8J/ (ចូលមើលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤)។

# ជំពូកទី៣
# អានុភាពនៃសេចក្ដីសម្រេច

# ជំពូកទី ៣
# អានុភាពនៃសេចក្តីសម្រេច

សេចក្តីដែលបានបកស្រាយ ក្នុងជំពូកនេះសំដៅដល់ អានុភាពនៃសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ (ផ្នែកទី១) និងអានុភាព នៃសេចក្តីសម្រេចរបស់តុលាការ (ផ្នែកទី២)។

## ផ្នែកទី១ អានុភាពនៃសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

នៅពេល មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិចេញសេចក្តីសម្រេចកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត សេចក្តីសម្រេចនោះនឹងត្រូវធ្វើឡើងជា ៤ ច្បាប់។ ១ ច្បាប់ សម្រាប់រក្សាទុកនៅ នាយកដ្ឋានអត្រានុកូលដ្ឋាន ដើម្បីកិបភ្ជាប់នឹងបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតដែលកំពុងរក្សាទុក ១ច្បាប់ សម្រាប់ចម្លងជូនរដ្ឋបាលរាជធានី ខេត្ត ១ ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកិបភ្ជាប់នឹងបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើតដែលកំពុងរក្សាទុក ហើយ ១ ច្បាប់ ចុងក្រោយ សម្រាប់សាមីអ្នកស្នើសុំ។[62]

ក្រោយពី ទទួលបានសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅ នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានកាតព្វកិច្ចមួយចំនួនដូចតទៅៈ[63]

ត្រូវកិបភ្ជាប់សេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ជាមួយបញ្ជីអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ដែលត្រូវធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពនោះ ។

ប្រសិនបើ ជាសេចក្តីសម្រេចកែតម្រូវទិន្នន័យ ត្រូវឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួស នូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យនោះ ដោយទឹកប៊ិកពណ៌ក្រហម (ដូចមានក្នុងឧបសម្ព័ន្ធទី៦)។

ចំណែក សេចក្តីសម្រេចមោឃភាពវិញ ត្រូវសរសេរដោយទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវមោឃភាពនោះ(ដូចមានក្នុងឧបសម្ព័ន្ធទី៧) ។

ចុងក្រោយ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើត ឬបញ្ជាក់កំណើត ស្របតាមសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិចំនួន ៣ ច្បាប់ ហើយប្រគល់ជូន សាមីខ្លួនអ្នកស្នើសុំដើម្បីប្រើប្រាស់តាមដែលអាចប្រើបាន។

[62] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

[63] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

## ផ្នែកទី២ អានុភាពនៃដីកាសម្រេចរបស់តុលាការ

ក្រោយពេលដីកាសម្រេចអំពីការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតចូលជាស្ថាពរ នឹងមានអានុភាពក្នុងការអនុវត្ត។អានុភាពនៃដីកាសម្រេចមាន ចំពោះសាមីខ្លួននៃបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត ព្រមទាំងដាក់កាតព្វកិច្ច ឱ្យមន្ត្រីអត្រានុលកូលដ្ឋានត្រូវអនុវត្តតាមដីកាសម្រេច។ស្រដៀងគ្នានឹងការស្នើសុំកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើតដោយមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិដែរ មន្ត្រីអត្រានុកូលដ្ឋានមានកាតព្វកិច្ចអនុវត្តតាមដីកាសម្រេចរបស់តុលាការ ដោយអាស្រ័យលើការទទួលបានការជូនដំណឹងអំពីដីកាសម្រេចនៅក្នុងឆ្នាំកំពុងអនុវត្ត ឬនៅក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន។

### ២.១ ក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន

ដោយសារតែ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការមិនទាន់ត្រូវបានអនុវត្តនៅឡើយ បើទោះបីជាបទប្បញ្ញត្តិឯទៀត នៃច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មត្រូវបានអនុវត្តចាប់តាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ក៏ដោយ ចំពោះបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងមាត្រា១៧៩ មាត្រា១៨០ និងមាត្រា១៨១ អាចអនុវត្តបាន លុះត្រាតែមានអនុក្រឹត្យកំណត់។[64]

ប្រសិនបើបទប្បញ្ញាត្តិ ស្តីអំពីការជូនដំណឹងដោយតុលាការត្រូវបានអនុវត្ត មន្ត្រីអត្រានុកូលដ្ឋានអាចធ្វើនីតិវិធីកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតបាន ទោះបីជាមិនទទួលបានការជូនដំណឹងអំពីដីកាសម្រេចពីអ្នកស្នើសុំក៏ដោយ។[65]

ក្នុងអំឡុងពេល រង់ចាំការអនុវត្តបទប្បញ្ញាត្តិ ស្តីពីការជូនដំណឹងដោយតុលាការ សាមីខ្លួន ឬអ្នកដែលមានផលប្រយោជន៏ពាក់ព័ន្ធត្រូវជូនដំណឹងអំពីដីកាសម្រេចដល់មន្ត្រីអត្រនានុកូលដ្ឋាន ដើម្បីអាចអនុវត្តនីតិវិធីកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតក្នុងគល់បញ្ជី។ ដើម្បីអាចជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋានបានត្រឹមត្រូវ គប្បីស្វែងយល់អំពី ការដាក់ពាក្យសុំ និងទីកន្លែងស្នើសុំ ឯកសារភ្ជាប់ជាមួយពេលដាក់ពាក្យស្នើសុំ និងការអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការនៅរដ្ឋបាលឃុំ សង្កាត់។

#### ២.១.១ ការដាក់ពាក្យសុំ និងទីតាំងដាក់ពាក្យសុំ

បន្ទាប់ពី ទទួលបានដីកាសម្រេចរបស់តុលាការ ក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីកំណើត ឬបញ្ជីបញ្ជាក់កំណើត សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នា អាចដាក់ពាក្យសុំ នៅរដ្ឋបាលឃុំ សង្កាត់ នៃទីតាំងដែលបានចុះបញ្ជីអត្រានុកូលដ្ឋាន

---

[64] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

[65] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៧ កថាខណ្ឌទី៦។

កន្លងមកបាន (ដូចមានក្នុងឧបសម្ព័ន្ធទី៨)។ តាមរយៈ សេចក្តីណែនាំលេខ០០៦សនណឆ្នាំ២០២៤ មិនបាន កំណត់រយៈពេល ក្នុងការជូនដំណឹងទៅ រដ្ឋបាលឃុំ សង្កាត់ បន្ទាប់ពីដីកាសម្រេចរបស់តុលាការបានចូលជាស្ថាពរនោះទេ ប៉ុន្តែបើក្រឡេកមើល ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ បានកំណត់អំឡុងពេល១៥ថ្ងៃ បន្ទាប់ពីដីកាបានសម្រេចចូលជាស្ថាពរ។[66] ទោះបីជា បានកំណត់អំឡុងពេលជាក់លាក់ក្នុងការជូនដំណឹងទៅរដ្ឋបាលឃុំ សង្កាត់បែបនេះក៏ដោយ ប៉ុន្តែមិនបានកំណត់នូវទណ្ឌកម្មណាមួយចំពោះ ការយឺតយ៉ាវ ឬការខកខានមិនបានជូនដំណឹងទាន់ពេលវេលាកំណត់ ឬផលវិបាកនៅពេលហួសអំឡុងពេលកំណត់នេះឡើយ។

### ២.១.២ ឯកសារភ្ជាប់ពេលដាក់ពាក្យស្នើសុំ

ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣ បានចង្អុលបង្ហាញ ឱ្យអ្នកដាក់ពាក្យស្នើសុំភ្ជាប់មកជាមួយឯកសារចំនួនពីរប៉ុណ្ណោះគឺ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃដីកាសម្រេចរបស់តុលាការ និងសេចក្តីបញ្ជាក់អំពីថ្ងៃ ដែលសេចក្តីសម្រេចចូលជាស្ថាពរ។

ប៉ុន្តែ សេចក្តីណែនាំលេខ០០៦សនណឆ្នាំ២០២៤ បានកំណត់ថា នៅពេលជូនដំណឹងទៅកាន់មន្ត្រីអត្រានុកូលដ្ឋាន អ្នកដាក់ពាក្យសុំ ត្រូវភ្ជាប់ជាមួយឯកសារមួយចំនួនដូចជា៖ សេចក្តីសម្រេចរបស់តុលាការច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់នីត្យានុកូលកម្ម សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅរបស់អ្នកដាក់ពាក្យស្នើសុំ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬឯកសារបញ្ជាក់អត្តសញ្ញាណផ្សេងទៀត របស់អ្នកដាក់ពាក្យសុំ។

សេចក្តីណែនាំលេខ០០៦សនណឆ្នាំ២០២៤ តម្រូវឱ្យភ្ជាប់ឯកសារពាក់ព័ន្ធផ្សេងទៀត ក្រៅពីដីកាសម្រេចរបស់តុលាការ ប្រហែលជាមានគោលបំណងធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់ឱ្យបានច្បាស់លាស់ ក៏ប៉ុន្តែហាក់បីដូចជាមិនមានភាពចាំបាច់នោះទេ ពីព្រោះថាមុនតុលាការចេញសេចក្តីសម្រេច គឺបានឆ្លងកាត់ការពិនិត្យ និងវិនិច្ឆ័យលើឯកសារពាក់ព័ន្ធសព្វគ្រប់រួចហើយ។ ដូចនេះទោះបីជា តុលាការសម្រេចខុស ក៏មន្ត្រីអត្រានុកូលដ្ឋានត្រូវតែអនុវត្តតាមសេចក្តីសម្រេច ហើយក៏មិនទទួលខុសត្រូវចំពោះការចុះបញ្ជីខុសនោះដែរ។

### ២.១.៣ ការអនុវត្តសេចក្តីសម្រេចរបស់តុលាការនៅរដ្ឋបាលឃុំ សង្កាត់

ក្រោយពេលទទួលបានពាក្យស្នើសុំ មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ ត្រូវអនុវត្តនីតិវិធីដោយ ជាបឋមត្រូវពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋានកំណើត ជាមួយនឹងដីកាសម្រេចរបស់តុលាការ បន្ទាប់មក គិបភ្ជាប់ដីកាសម្រេចរបស់តុលាការ នៅលើបញ្ជីអាត្រានុកូលដ្ឋានកំណើតដែលត្រូវកែតម្រូវទិន្នន័យ ឬមោឃភាព រួចមក

[66] ច្បាប់អត្រានុកូលដ្ឋានឆ្នាំ២០២៣, មាត្រា៨៧។

កែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជំនួសនូវទិន្នន័យ ដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេង លើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យដោយទឹកប៊ិកពណ៌ក្រហម (ដូចមានក្នុងឧបសម្ព័ន្ធទី៩)។ រីឯការមោឃភាព ត្រូវសរសេរដោយទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេងលើបញ្ជីដែលត្រូវមោឃភាព (ដូចមានក្នុងឧបសម្ព័ន្ធទី១០)។ បន្ទាប់មកទៀត ត្រូវដកហូត សំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើត រួចហើយបោះត្រា មោឃភាព ព្រមទាំងរក្សាទុក នៅរដ្ឋបាលឃុំ សង្កាត់។ ចុងក្រោយ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើត ដែលបានកែតម្រូវទិន្នន័យរួច ស្របតាមសេចក្តីសម្រេចរបស់តុលាការចំនួន ៣ ច្បាប់ជូនសាមីខ្លួនប្រើប្រាស់ តាមដែលអាចប្រើបាន។[67]

## ២.២ នៅក្នុងឆ្នាំកន្លងផុតនៃការអនុវត្តការងារអត្រានុកូលដ្ឋាន

ក្នុងករណី ដែលដីកាសម្រេចរបស់តុលាការ បានចេញនៅពេលហួសឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន សាមីខ្លួន ឬអ្នកដែលមានផលប្រយោជន៍ពាក់ព័ន្ធ ត្រូវដាក់ពាក្យស្នើសុំ នៅទីតាំងដែលបានកំណត់ ដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធ ដើម្បីមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច អាចអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការបាន។

### ២.២.១ ការដាក់ពាក្យ និងទីកន្លែងស្នើសុំ

ក្រោយពេលទទួលបានសដីកាសម្រេចពីតុលាការ សាមីខ្លួន ឬអាណាព្យាបាល ឬញាតិជានីតិជនដែលមានឈ្មោះក្នុងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារជាមួយគ្នាអាចដាក់ពាក្យស្នើសុំនៅទីតាំងចំនួនពីរគឺ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃទីតាំងដែលបញ្ជីអត្រានុកូលដ្ឋានកំណើតរបស់សាមីខ្លួនបាននិងកំពុងរក្សាទុក (ដូចមាននៅក្នុងឧបសម្ព័ន្ធទី១១) ឬនៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ (ដូចមាននៅក្នុងឧបសម្ព័ន្ធទី១២)។

### ២.២.២ ឯកសារភ្ជាប់ពេលដាក់ពាក្យស្នើសុំ

ចំពោះ ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ ត្រូវអនុវត្តដូចករណីការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការនៅក្នុងឆ្នាំកំពុងអនុវត្តការងារអត្រានុកូលដ្ឋាន ដែលបានរៀបរាប់ក្នុងចំណុច (២.១.២ ឯកសារភ្ជាប់ពេលដាក់ពាក្យស្នើសុំ) ផ្នែកទី ២ នៃជំពូកទី៣។

### ២.២.៣ ការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

ក្រោយពីទទួលបានសេចក្តីសម្រេចរបស់តុលាការ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយកដ្ឋានអត្រានុកូល

[67] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

ដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចក្នុងការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត។

**ក. សមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

បន្ទាប់ពីទទួលបានដីកាសម្រេចកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតពីអ្នកស្នើសុំនិងរដ្ឋបាលរាជធានី ខេត្ត មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម៖ ទី១ ពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋានដែលកំពុងរក្សាទុក ជាមួយនឹងដីកាសម្រេចរបស់តុលាការ ទី២ ថតចម្លងដីកាសម្រេចរបស់តុលាការចំនួន ៥ច្បាប់ រួចបោះត្រាចូលរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះ ១ច្បាប់ សម្រាប់កិបភ្ជាប់ទៅនឹងបញ្ជីអត្រានុកូលដ្ឋានកំណើត ១ច្បាប់ សម្រាប់បញ្ជូនទៅកាន់រដ្ឋបាលរាជធានី ខេត្ត ១ច្បាប់ សម្រាប់បញ្ជូន ទៅនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ១ច្បាប់សម្រាប់ជូនសាមីខ្លួន និង ១ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលឃុំ សង្កាត់ ដើម្បីចេញសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើមថ្មី។ ទី៣ កែតម្រូវទិន្នន័យ ដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួស នូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេង លើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យ ដោយទឹកប៊ិកពណ៌ក្រហម។ ទី៤ បើជាការមោឃភាព ត្រូវសរសេរដោយទឹកប៊ិកពណ៌ក្រហមនៅលើរឹមទំព័រខាងឆ្វេង លើបញ្ជីដែលត្រូវមោឃភាព។ ទី៥ ត្រូវដកហូតសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើតចាស់ទាំងអស់ ដែលតុលាការបានកែតម្រូវ ទិន្នន័យ ឬមោឃភាព បន្ទាប់មកមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវបោះត្រា *"មោឃៈ"* រួចរក្សាទុក នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទី៦ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើត តាមបញ្ជីអត្រានុកូលដ្ឋានកំណើតដែលបានកែតម្រូវទិន្នន័យរួច ស្របតាមដីកាសម្រេចរបស់តុលាការចំនួន ៣ ច្បាប់។ ទី៧ បញ្ជូនដីកាសម្រេចរបស់តុលាការពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានរបស់អ្នកស្នើសុំ មកនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម តាមរយៈរដ្ឋបាលរាជធានី ខេត្ត និងចុងក្រោយ ក្នុងករណីដែលការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត តាមសេចក្តីសម្រេចរបស់តុលាការ ដែលបានទទួលពី នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មន្ត្រីរក្សាសៀវភៅ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ស្របតាមដីកាសម្រេចរបស់តុលាការ។[68]

**ខ. សមត្ថកិច្ចរបស់នាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

បន្ទាប់ពីទទួលបានដីកាសម្រេចរបស់តុលាការពីអ្នកស្នើសុំ ឬរដ្ឋបាលរាជធានី ខេត្ត នាយកដ្ឋានអត្រានុកូល

[68] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

ដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវអនុវត្តនូវភារកិច្ច ក្នុងការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដូចខាងក្រោម៖

ជាដំបូង ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់បញ្ជីអត្រានុកូលដ្ឋានកំណើតដែលកំពុងរក្សាទុក ជាមួយនឹងដីកាសម្រេចរបស់តុលាការ បន្ទាប់មកត្រូវថតចម្លងដីកាសម្រេចរបស់តុលាការចំនួន ៤ ច្បាប់ រួចបោះត្រាចូលនាយកដ្ឋានអត្រានុកូលដ្ឋាន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដោយក្នុងនោះ ១ ច្បាប់ សម្រាប់កិបភ្ជាប់ទៅនឹងបញ្ជីអត្រានុកូលដ្ឋានកំណើត ១ ច្បាប់សម្រាប់បញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត ១ ច្បាប់ សម្រាប់បញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង ១ ច្បាប់សម្រាប់ជូនអ្នកស្នើសុំ។[69]

ក្នុងករណី ជាដីកាសម្រេចកែតម្រូវទិន្នន័យ ត្រូវកែតម្រូវដោយឆូតទិន្នន័យដែលខុសដោយទឹកប៊ិកពណ៌ក្រហម និងសរសេរជួសនូវទិន្នន័យដែលត្រឹមត្រូវដោយទឹកប៊ិកពណ៌ខៀវ ព្រមទាំងសរសេរនៅលើរឹមទំព័រខាងឆ្វេង លើបញ្ជីដែលត្រូវកែតម្រូវទិន្នន័យ ដោយទឹកប៊ិកពណ៌ក្រហម។ រីឯ ករណីជាដីកាសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ត្រូវមោឃភាព ដោយសរសេរទឹកប៊ិកពណ៌ក្រហម នៅលើរឹមទំព័រខាងឆ្វេងបញ្ជី ដែលត្រូវមោឃភាពនោះ។

បន្ទាប់មកទៀត ត្រូវដកហូតសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានចាស់ទាំងអស់ដែលតុលាការបានកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត រួចមកមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវបោះត្រា *"មោឃៈ"* រួចរក្សាទុកនៅនាយកដ្ឋានអត្រានុកូលដ្ឋាន។ បន្ទាប់ពីដកហូតសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើតចាស់ ត្រូវចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានកំណើតថ្មី ស្របតាមបញ្ជីអត្រានុកូលដ្ឋានដែលបានកែតម្រូវរួច ដោយដីកាសម្រេចរបស់តុលាការ ចំនួន ៣ ច្បាប់ ជូនសាមីខ្លួន ដើម្បីប្រើប្រាស់តាមដែលអាចប្រើបាន។ ក្រោយមកទៀត ត្រូវបញ្ជូនដីកាសម្រេចរបស់តុលាការ ពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋានរបស់អ្នកស្នើសុំទៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈរដ្ឋបាលរាជធានី ខេត្ត និងចុងក្រោយ នាយកដ្ឋានអត្រានុកូលដ្ឋានត្រូវលើកយោបល់ជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ពិនិត្យសម្រេចចេញសំបុត្រអត្រានុកូលដ្ឋានថ្មី។[70]

[69] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

[70] សេចក្តីណែនាំលេខ០០៦សនណ២០២៤។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងសរសេរអត្ថបទសារណាពាក់ព័ន្ធនឹងប្រធានបទស្តីអំពី ការកែតម្រូវបញ្ជីកំណើតនេះរួចមក យើងខ្ញុំកាន់តែយល់ដឹងយ៉ាងច្បាស់ថា បញ្ជីអត្រានុកូលដ្ឋានកំណើត ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ បុគ្គលផ្ទាល់ខ្លួន ដែលជាឯកសារសម្រាប់បញ្ជាក់អត្តសញ្ញាណ ជាតិ កំណើតរបស់បុគ្គលដ៏រឹងមាំមួយ ហើយបញ្ជីអត្រានុកូលដ្ឋានកំណើត មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់បុគ្គលនោះទេ ថែមទាំងផ្តល់ប្រយោជន៍ដល់សង្គមជាតិផងដែរ តាមរយៈការពង្រឹងនីតិរដ្ឋ លើកកម្ពស់កិត្យានុភាពជាតិ និងជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ រាល់ទិន្នន័យដែលមានចុះក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត សុទ្ធសឹងតែទិន្នន័យសំខាន់សម្រាប់សំគាល់អត្តសញ្ញាណបុគ្គលម្នាក់ៗដូចជា ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ និងទីកន្លែងកំណើត រួមទាំងទិន្នន័យអត្តសញ្ញាណរបស់ឪពុក និងរបស់ម្តាយផងដែរ។ ដូចនេះ ប្រសិនបើមានការចុះបញ្ជីអត្រានុកូលដ្ឋានកំណើតបណ្តាលឱ្យមានកំហុសទិន្នន័យត្រង់ចំណុចណាមួយ ទោះជាកំហុសរបស់មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច ឬជាកំហុសផ្ទាល់របស់សាមីខ្លួនអ្នកប្រើប្រាស់ឯកសារក៏ដោយ មិនអាចធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពដោយឯកឯងបានឡើយ។ មានតែអាជ្ញាធរមានសមត្ថកិច្ចដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ផ្តល់សមត្ថកិច្ចឱ្យប៉ុណ្ណោះ ទើបមានសិទ្ធិក្នុងការកែតម្រូវ ដូចជាមន្ត្រីអត្រានុកូលដ្ឋាន និងតុលាការជាដើម។

ឆ្លងតាមការពិភាក្សាខាងលើ បានបង្ហាញថា មូលហេតុ ឬកត្តាចម្បង ដែលបណ្តាលឱ្យមានកំហុសទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានកំណើត ភាគច្រើនកើតឡើងដោយសារកំហុសរបស់មន្ត្រីអត្រានុកូលដ្ឋានឃុំសង្កាត់ នៅពេលដែលចុះបញ្ជីខ្វះការប្រុងប្រយ័ត្ន ដោយសរសេរអក្សរមិនស្អាត ឬខុសអក្ខរាវិរុទ្ធ ហេតុនេះសមត្ថភាពរបស់មន្ត្រីអត្រានុកូលដ្ឋាន និងការចុះបញ្ជីដោយដៃគឺជាបញ្ហាប្រឈមមួយ ដែលបង្កឱ្យមានបញ្ហាខាងលើ។ ទន្ទឹមនឹងនេះ កត្តាប្រជាពលរដ្ឋផ្ទាល់ក៏ជាដើមហេតុបណ្តាលឱ្យមានកំហុសទិន្នន័យដែរ ហេតុនេះអាចស្តែងឱ្យឃើញពីភាពខ្វះខាតចំណេះដឹងពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារអត្រានុកូលដ្ឋាន ជាពិសេសបញ្ជីអត្រានុកូលដ្ឋានកំណើតនេះតែម្តង។

ចំណែក បែបបទ នីតិវិធីក្នុងការកែតម្រូវ និងមោឃភាព ទោះបីជាច្បាប់អត្រានុកូលដ្ឋាន ស្តិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ បានកំណត់ អំពីបែបបទ នីតិវិធីក្នុងការកែតម្រូវ និងមោឃភាពក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនផងដែរ ចំពោះការអនុវត្តការងាររបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការកែតម្រូវ ឬមោឃភាព។

ចំពោះ ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយតុលាការ យើងខ្ញុំសង្កេតឃើញថា មានអនិយ័តភាពក្នុងការអនុវត្ត ដោយហេតុថា ច្បាប់អត្រានុកូលដ្ឋាន ស្តិតិអត្រានុកូលដ្ឋាន និងអត្ត

សញ្ញាណកម្ម ត្រង់មាត្រា ៨៧ កថាខណ្ឌទី២ បានកំណត់ថា បទប្បញ្ញត្តិ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាណ្តឹង ត្រូវយកមកអនុវត្តចំពោះ ករណីការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ប៉ុន្តែបើយើងពិនិត្យមើល ស្មារតីមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ច្បាប់នេះអាចអនុវត្តបានចំពោះករណីណាមួយ លុះត្រាតែ ករណីនោះមានកំណត់ជាក់លាក់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ នៃច្បាប់នេះតែប៉ុណ្ណោះ។

បើយើងក្រឡេកមើល បញ្ជីនៃតារាង ឧបសម្ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មិនបានកំណត់អំពីចំណុចនៃការកែ តម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានឡើយ ហេតុ នេះ ការអនុវត្តរបស់តុលាការចំពោះការកែតម្រូវ និងមោឃភាព គឺជាការអនុវត្តមិនត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិច្បាប់។

បញ្ហាប្រឈមមួយទៀត ដែលបង្កជាការលំបាកដល់ពលរដ្ឋគឺ ការជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋាន នូវសេចក្តីសម្រេចតុលាការ ដោយខ្លួនឯងផ្ទាល់។ ពោល ក្រោយពេលតុលាការចេញសេចក្តីសម្រេចកែតម្រូវរួច ហើយ ពលរដ្ឋដែលជាអ្នកដាក់ពាក្យសុំទៅតុលាការ ត្រូវជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋាន ដើម្បីកែតម្រូវតាមសេចក្តីសម្រេចរបស់តុលាការ ដោយខ្លួនឯង ដោយត្រូវគោរពតាមនីតិវិធី ដែលកំណត់ក្នុងសេចក្តីណែនាំលេខ ០០៦សនណឆ្នាំ២០២៤ ដែលបង្កឱ្យមានលក្ខណៈស្មុគស្មាញថែមទៀត។ បញ្ហានេះកើតឡើង ដោយសារតែ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ នៃច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មមិនទាន់ត្រូវបានអនុវត្តនៅឡើយ។

រីឯ ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតដោយមន្ត្រីអត្រានុកូលដ្ឋាន យើងខ្ញុំសង្កេតឃើញថា បែបបទ នីតិវិធីមិនមានលក្ខណៈស្មុគស្មាញគួរឱ្យកត់សម្គាល់នោះទេ។ ប៉ុន្តែទោះជាយ៉ាងណានៅតែមានការត្អូញត្អែររបស់ពលរដ្ឋពាក់ព័ន្ធនឹងការចំណាយពេលវេលាយូរក្នុងការកែតម្រូវ ការទាមទារផលប្រយោជន៍ផ្សេងៗដែលច្បាប់មិនតម្រូវជាដើម ដែលកត្តាទាំងនេះមិនមែនជាបញ្ហាផ្នែកនីតិវិធីទេ គឺអាចបណ្តាលមកពីបញ្ហាបុគ្គលតែប៉ុណ្ណោះ តែក៏ទាមទារឱ្យមានការគិតគូរពីអាជ្ញាធរមានសមត្ថកិច្ចផងដែរ ដើម្បីដោះស្រាយទុក្ខកង្វល់របស់ពលរដ្ឋ។

សរុបជារួម ការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើតបានដោះស្រាយបញ្ហានៅចំពោះមុខ ដែលបានកើតឡើងដោយកត្តាអចេតនាផ្សេងៗ ហើយបែបបទ នីតិវិធីក្នុងការកែតម្រូវ ឬមោឃភាពត្រូវបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ប៉ុន្តែការអនុវត្តមានភាពឆកល្វែង និងជួបប្រទះបញ្ហាប្រឈម ដែលទាមទារឱ្យមានការដោះស្រាយ និងកែសម្រួល ដើម្បីទទួលបានលទ្ធផលកាន់តែល្អប្រសើរជាងនេះ ជាលំដាប់។

# អនុសាសន៍

# អនុសាសន៍

ស្របតាមការពិភាក្សាខាងលើ ជាលទ្ធផលយើងខ្ញុំបានប្រទះឃើញ បញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធនឹងក្នុងវង្វង់នៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដែលបានលើកឡើងក្នុងសេចក្ដីសន្និដ្ឋានខាងលើ។ជាសង្ខេប បញ្ហាប្រឈមដែលបានលើកឡើងខាងលើរួមមាន ប្រភព និងឫសគល់ដែលបណ្តាលឱ្យមានកំហុសទិន្នន័យ អនិយ័តភាពនៃការអនុវត្តច្បាប់ដោយតុលាការ ការមិនទាន់ដាក់ឱ្យអនុវត្តបទប្បញ្ញត្តិមួយចំនួននៃច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ជាដើម។

អាស្រ័យហេតុនេះ យើងខ្ញុំសូមអនុញ្ញាតលើកឡើងនូវគំនិត ទស្សនៈ និងការយល់ឃើញផ្ទាល់ខ្លួនមួយចំនួន ផ្អែកតាមការសិក្សាស្រាវជ្រាវកន្លងមក ដែលប្រហែលជាអាចដោះស្រាយបញ្ហាប្រឈមដែលចោទឡើងដូចជា ត្រូវពង្រឹងការអប់រំ និងបណ្ដុះបណ្ដាលមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់បន្ថែម ចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន ដើម្បីកាត់បន្ថយកំហុសឆ្គងដែលកើតមានកន្លងមក និងបន្តបង្កើនការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីចំណេះដឹង ក្នុងការប្រើប្រាស់ឯកសារបញ្ជីអត្រានុកូលដ្ឋានឱ្យបានត្រឹមត្រូវ។ លើសពីនេះទៀត ត្រូវធ្វើទំនើបកម្មប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ពីការចុះបញ្ជីដោយដៃ ទៅជាការចុះបញ្ជីដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឱ្យបានឆាប់រហ័ស ដែលវាជាដំណោះស្រាយសំខាន់មួយ ជួយកាត់បន្ថយកំហុសទិន្នន័យបាន។

ចំណែក អនិយ័តភាពនៃការអនុវត្តច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ចំពោះការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ដោយតុលាការគឺ គួរតែធ្វើការបញ្ចូលចំណុច ស្ដីពីការការកែតម្រូវ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន ទៅក្នុងបញ្ជីនៃតារាងឧបសម្ព័ន្ធ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ដើម្បីឱ្យការអនុវត្តត្រឹមត្រូវតាមច្បាប់។

ជាចុងក្រោយ បទប្បញ្ញត្តិពាក់ព័ន្ធនឹងការជូនដំណឹងដោយតុលាការ នៃច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលមិនទាន់ត្រូវបានអនុវត្ត គប្បីសិក្សាក្នុងការដាក់ឱ្យអនុវត្តឱ្យបានឆាប់រហ័ស ពីព្រោះវាអាចជួយសម្រាលបន្ទុករបស់អ្នកដាក់ពាក្យសុំទៅតុលាការ ដោយមិនចាំបាច់ធ្វើការជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋានដោយខ្លួនឯង អំពីសេចក្ដីសម្រេចរបស់តុលាការ ហើយថែមទាំងកាត់បន្ថយនីតិវិធីក្នុងការដាក់ពាក្យសុំទៅមន្ត្រីអត្រានុកូលដ្ឋានថែមទៀត។

# គន្លនិខ្មេល

# គន្ថនិទ្ទេស

## ច្បាប់

១. ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។

២. ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

៣. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

៤. ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, នស/រកម/០៧២៣/០០៩, ០១ កក្កដា ២០២៣។

## អនុក្រឹត្យ

៥. អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២៩ ធ្នូ ២០០០។

៦. អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា ៨ និងមាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន, លេខ៦០អនក្រ.បក, ២៤ មិថុនា ២០០២។

៧. អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ១៧អនក្រ.បក, ១៤ មិថុនា ២០០៤។

៨. អនុក្រឹត្យស្តីពីការកែសម្រួលចំណុច ក និង ខ មាត្រា ៥៩ ថ្មីស្ទួន, លេខ១០៦អនក្រ.បក, ២៣ សីហា ២០០៥។

៩. អនុក្រឹត្យស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ, លេខ១៣៤អនក្រ.បក, ០៥ កក្កដា ២០១៦។

## សេចក្តីណែនាំ

១០. សេចក្តីណែនាំស្តីពីការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៣៥សណន, ២០ តុលា ២០១៧។

១១. សេចក្តីណែនាំស្តីពីការបន្តដំណើរការកែតម្រូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន, លេខ០៤៥សណន, ២៣ ធ្នូ ២០១៩។

១២. សេចក្តីណែនាំស្តីពីបែបបទ និតិវិធីនៃការកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន, លេខ០០៦សណន, ០៧ មីនា ២០២៤។

១៣. សេចក្តីណែនាំលើការអនុវត្តការងារអត្តសញ្ញាណកម្ម, លេខ០០១សណន, ២៧ មីនា ២០២៤។

## ផ្សេងៗ

១៤. គណៈកម្មាការជាតិគាំទ្រឃុំ សង្កាត់, *កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន* (ភ្នំពេញ ៖ គណៈកម្មាការជាតិគាំទ្រឃុំ សង្កាត់, ២០០៥)។

១៥. សេចក្តីជូនដំណឹង, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ០៣ សីហា ២០២០។

១៦. សេចក្តីបំភ្លឺ, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ០៦ វិច្ឆិកា ២០២៣។

១៧. សេក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលរយៈពេល ៦ខែ នៃយុទ្ធនាការជំរុញនិងពន្លឿនរឿងក្តីនៅតាមតុលាការនិងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រកតីនៅតាមតុលាការ, ក្រសួងយុត្តិធម៌, ១១ កក្កដា ២០២៤។

## គេហទំព័រ

១៨. https://www.information.gov.kh/articles/122141 (ចូលមើលថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤) ។

១៩. https://www.facebook.com/share/v/jhNUQsyJXGsvonAn/?mibextid=Le6z7H (ចូលមើលថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២៤) ។

២០. https://vt.tiktok.com/ZS2Ryra8J/ (ចូលមើលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤) ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** របៀបកែតម្រូវទិន្នន័យបញ្ជីកំណើត ក្នុងឆ្នាំកំពុងអនុវត្ត

**ឧបសម្ព័ន្ធទី២៖** របៀបមោឃភាពទិន្នន័យបញ្ជីបញ្ជាក់កំណើត ក្នុងឆ្នាំកំពុងអនុវត្ត

- របៀបមោឃៈលើបញ្ជីបញ្ជាក់កំណើតដែលសរសេរខុសមិនអាចកែបាន
- របៀបមោឃៈលើសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតមួយក្បាលទៀត

**ឧបសម្ព័ន្ធទី៣៖** ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត ក្នុងឆ្នាំកន្លងផុត

- ពាក្យស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋានកំណើត
- ពាក្យស្នើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋានកំណើត

**ឧបសម្ព័ន្ធទី៤៖** គំរូពាក្យសុំសេចក្តីសម្រេចនៅតុលាការ

**ឧបសម្ព័ន្ធទី៥៖** គំរូលិខិតបញ្ជាក់អត្តសញ្ញាណ

**ឧបសម្ព័ន្ធទី៦៖** របៀបកែតម្រូវទិន្នន័យតាមសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងឆ្នាំកន្លងផុត

**ឧបសម្ព័ន្ធទី៧៖** របៀបមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ក្នុងឆ្នាំកន្លងផុត

**ឧបសម្ព័ន្ធទី៨៖** ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ

**ឧបសម្ព័ន្ធទី៩៖** របៀបកែតម្រូវទិន្នន័យ បញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ

**ឧបសម្ព័ន្ធទី១០៖** របៀបមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ

**ឧបសម្ព័ន្ធទី១១៖** ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

**ឧបសម្ព័ន្ធទី១២៖** ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្តីសម្រេចរបស់តុលាការ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

# ឧបសម្ព័ន្ធទី១៖
# របៀបកែតម្រូវទិន្នន័យបញ្ជីដ្ឋាន
# កំណើត ក្នុងឆ្នាំកំពុងអនុវត្ត

យល់ព្រមលុបពាក្យ **សិសា**

និងយល់ព្រមសរសេរពាក្យ **សិលា** ជំនួសវិញ។

ធ្វើនៅថ្ងៃទី...ខែ...ឆ្នាំ...

ស្នាមមេដៃ. ហត្ថលេខា

អ្នករាយការណ៍ មន្ត្រីអត្រានុកូលដ្ឋាន

**ខេត្ត ក្រុង** ................................ **លេខ** ...... *០១*..........................

**ស្រុក ខណ្ឌ** ................................ **សៀវភៅកំណើតលេខ** ...........

**ឃុំ សង្កាត់** ................................ **ឆ្នាំ** ........................................

# បញ្ជីកំណើត

| | | | ភេទ | សញ្ជាតិ |
|---|---|---|---|---|
| នាមត្រកូល | | *សាន* | *ប្រុស* | *ខ្មែរ* |
| នាមខ្លួនទារក | | ~~សិសា~~ *សិលា* | | |
| ជាអក្សរឡាតាំង | នាមត្រកូល | **SAN** | កូនទី *មួយ* | មាន ឬឥតខាន់ស្លា *មានខាន់ស្លា* |
| | នាមខ្លួនទារក | **SILA** | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | ថ្ងៃ *សៅរ៍* ទី *២២* ខែ *មិថុនា* ឆ្នាំ *២០២៤* | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | *ភូមិភ្លើងឆេះរទេះ សង្កាត់ភ្លើងឆេះរទេះ ខណ្ឌកំបូល រាជធានីភ្នំពេញ*<br>*ប្រទេសកម្ពុជា* | | |

| ឪពុក ម្តាយទារក | ឪពុក | | ម្តាយ | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន | | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង | | | | |
| សញ្ជាតិ | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | | | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | ..................<br>..................<br>.................. | | ..................<br>..................<br>.................. | |
| មុខរបរពេលទារកកើត | | | | |
| ទីលំនៅពេលទារកកើត | | | | |
| លេខ អត្តសញ្ញាណប័ណ្ណ | | | | |

| | | ភេទ | ឆ្នាំកំណើត | សញ្ជាតិ |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍កំណើតទារក | | | | |
| ត្រូវជាអ្វីនឹងទារក | | | | |
| មុខរបរបច្ចុប្បន្ន | | | | |
| ទីលំនៅបច្ចុប្បន្ន | | | | |
| លេខអត្តសញ្ញាណប័ណ្ណ | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានអោយប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

ធ្វើនៅ..................... ថ្ងៃទី.......... ខែ.................. ឆ្នាំ...........

**ស្នាមមេដៃស្តាំអ្នករាយការណ៍** **មន្ត្រីអត្រានុកូលដ្ឋាន**

# ឧបសម្ព័ន្ធទី២៖
# របៀបមោឃភាពបញ្ជីបញ្ជាក់កំណើត
# ក្នុងឆ្នាំកំពុងអនុវត្ត

ខេត្ត ក្រុង (១).......　　　　　　　　　　លេខ (៤)............. ..............................

ស្រុក ខណ្ឌ (២)......　　　　　　　　　　សៀវភៅកំណើតលេខ (៥)...

ឃុំ សង្កាត់ (៣).......　　　　　　　　　　ឆ្នាំ (៦)........... ..............................

# សំបុត្របញ្ជាក់កំណើត

| | | | | | |
|---|---|---|---|---|---|
| នាមត្រកូល (៧) | | ស សំណាង | ភេទ (៩) | សញ្ជាតិ (១០) | កូនទី (១១) |
| នាមខ្លួនអ្នកកើត (៨) | | | ប្រុស | ខ្មែរ | បី |
| ជាអក្សរឡាតាំង (១២) | នាមត្រកូល | Sor Samnang | | | |
| | នាមខ្លួនអ្នកកើត | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៣) | | ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩ | | | |
| ទីកន្លែងកំណើត (១៤) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | ..... ភូមិព្រែកចារ ឃុំសំបូរ ស្រុកល្វាឯម ខេត្តកណ្តាល ប្រទេសកម្ពុជា ........................ | | | |

| ឪពុក ម្តាយ | ឪពុក | | ម្តាយ | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៥) | (១៦) | រស់ ឬស្លាប់ | | រស់ ឬស្លាប់ |
| ជាអក្សរឡាតាំង (១៧) | | | | |
| សញ្ជាតិ (១៨) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | | | | |
| ទីកន្លែងកំណើត (២០) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | | | |
| មុខរបរបច្ចុប្បន្ន (២១) | | | | |
| ទីលំនៅបច្ចុប្បន្ន (២២) | | | | |

ទុកជាមោឃៈ

ធ្វើនៅ.......ថ្ងៃទី......ខែ......ឆ្នាំ....

មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ

(ហត្ថលេខា និងត្រា)

(ឈ្មោះ)

| អំពីសាក្សី | សាក្សី | | សាក្សី | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួន (២៣) | (២៤) | ភេទ | | ភេទ |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | (២៦) | សញ្ជាតិ | | សញ្ជាតិ |
| ទីកន្លែងកំណើត (២៧) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | | | |
| មុខរបរបច្ចុប្បន្ន (២៨) | | | | |
| ទីលំនៅបច្ចុប្បន្ន (២៩) | | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣២) ធ្វើនៅ.... ....... ថ្ងៃទី ខែ ឆ្នាំ

(៣១) **ស្នាមមេដៃស្តាំ**　　　　　　　　　　(៣៣) **មន្ត្រីអត្រានុកូលដ្ឋាន**

សាមីខ្លួន សាក្សី　　　　សាក្សី　　　　　　**មេឃុំ**

(៣៤)

ដោយសារបញ្ជីអត្រានុកូលដ្ឋានមួយក្បាលទៀត

សរសេរខុសមិនអាចកែតម្រូវបាន ហើយទុកជាមោឃៈ

## ទុកជាមោឃៈ

ធ្វើនៅ..........ថ្ងៃទី...........ខែ......ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

មេឃុំ ឬចៅសង្កាត់

(ហត្ថលេខា និងត្រា)

# ឧបសម្ព័ន្ធទី៣៖
# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាព
# បញ្ជីអត្រានុកូលដ្ឋានកំណើត
# ក្នុងឆ្នាំកន្លងផុត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................. កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ............. ក្រុមទី........... ភូមិ......................... ឃុំ/សង្កាត់.................................... ក្រុង/ស្រុក/ខណ្ឌ......................... រាជធានី/ខេត្ត......................... ត្រូវជា[១] .............................។

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំកែតម្រូវទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន..................................................។
**យោង** : [២]......................................................................................................
.......................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន......................... របស់ឈ្មោះ............................. ភេទ..... កើតថ្ងៃទី..... ខែ.......... ឆ្នាំ.......... និងរបស់ឈ្មោះ............................. ភេទ..... កើតថ្ងៃទី..... ខែ.......... ឆ្នាំ.......... ត្រង់បញ្ជីលេខ............. នៅក្នុងសៀវភៅលេខ......... ឆ្នាំ........... ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី.................................. ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់.................... ក្រុង/ស្រុក/ខណ្ឌ...................... រាជធានី/ខេត្ត...................... មានកំហុសឆ្គងទិន្នន័យដែលមិនអាចប្រើប្រាស់បាន។

ដូចនេះខ្ញុំបាទ/នាងខ្ញុំ គោរពស្នើសុំធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានដូចខាងក្រោម ត្រង់៖

ខ្ទង់.................. របស់...................... ពី........................ ទៅ..............................
ខ្ទង់.................. របស់...................... ពី........................ ទៅ..............................
ខ្ទង់.................. របស់...................... ពី........................ ទៅ..............................
ខ្ទង់.................. របស់...................... ពី........................ ទៅ..............................
ខ្ទង់.................. របស់...................... ពី........................ ទៅ.............................. ជំនួសវិញ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការសុំកែតម្រូវខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាធ្វើការកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ................... ខែ................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
**ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ**

លេខ: ...................
បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្តាំនេះពិតស្នាមមេដៃរបស់ឈ្មោះ.............................. ពិតប្រាកដមែន។
ថ្ងៃ................... ខែ................. ឆ្នាំ......... ស័ក ព.ស.២៥...
ធ្វើនៅ.................... ថ្ងៃទី......... ខែ........... ឆ្នាំ២០...
**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. កើតថ្ងៃទី.......... ខែ.......... ឆ្នាំ................មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............ ផ្លូវ.............. ក្រុមទី............ ភូមិ..........................ឃុំ/សង្កាត់........................................... ក្រុង/ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត..........................ត្រូវជា⁽¹⁾ ..................................។

**សូមគោរពជូន**
**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**
**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំមោឃភាពបញ្ជីអត្រានុកូលដ្ឋាន........................................................។
**យោង** : ⁽²⁾.........................................................................................................................
...............................................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន......................... របស់ឈ្មោះ.................................ភេទ......កើតថ្ងៃទី......ខែ............ឆ្នាំ............បានចុះបញ្ជីចំនួន ............ដង មានដូចខាងក្រោម៖

ចុះបញ្ជីលើកទី១ ត្រង់បញ្ជីលេខ............នៅក្នុងសៀវភៅលេខ...... ..........ឆ្នាំ...... .........នៅក្នុងឃុំ/សង្កាត់ ................................ ក្រុង/ស្រុក/ខណ្ឌ........................ ............រាជធានី/ខេត្ត........ ......... ...................

ចុះបញ្ជីលើកទី២ ត្រង់បញ្ជីលេខ............នៅក្នុងសៀវភៅលេខ...... ..........ឆ្នាំ...... .........នៅក្នុងឃុំ/សង្កាត់ ................................ ក្រុង/ស្រុក/ខណ្ឌ........................ ............រាជធានី/ខេត្ត........ ......... ...................

ចុះបញ្ជីលើកទី៣ ត្រង់បញ្ជីលេខ............នៅក្នុងសៀវភៅលេខ...... ..........ឆ្នាំ......... ......នៅក្នុងឃុំ/សង្កាត់ ................................ ក្រុង/ស្រុក/ខណ្ឌ........................ ............រាជធានី/ខេត្ត........ ......... ...................

ដែលផ្ទុយនឹងមាត្រា ៦៣ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន។

ផ្អែកលើកំហុសឆ្គងខាងលើ ខ្ញុំបាទ/នាងខ្ញុំ ស្នើសុំធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើកទី...... និងសុំរក្សាទុកបញ្ជីអត្រានុកូលដ្ឋានដែលបានចុះលើកទី.........ដើម្បីប្រើប្រាស់ជាផ្លូវការ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការធ្វើមោឃភាពខាងលើនេះចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាពិនិត្យសម្រេចមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ.....................ខែ.....................ឆ្នាំ.........ស័ក ព.ស.២៥...
ធ្វើនៅ..................... ថ្ងៃទី......... ខែ............ ឆ្នាំ២០...
ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខ: ..................
បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្តាំនេះពិតស្នាមមេដៃរបស់ឈ្មោះ.................................. ពិតប្រាកដមែន។
ថ្ងៃ.....................ខែ.....................ឆ្នាំ.........ស័ក ព.ស.២៥...
ធ្វើនៅ..................... ថ្ងៃទី......... ខែ............ ឆ្នាំ២០...
**ប្រធាននាយកដ្ឋាន/អភិបាលក្រុង ស្រុក ខណ្ឌ**

# ឧបសម្ព័ន្ធទី៤៖
# គំរូពាក្យសុំដីកាសម្រេចនៅតុលាការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣❖៤៤

# ពាក្យសុំដីកាសម្រេច

**អ្នកដាក់ពាក្យសុំ** ឈ្មោះ........................ ភេទ........ កើតថ្ងៃទី........ ខែ........ ឆ្នាំ........
សញ្ជាតិ................ មុខរបរ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ........... ផ្លូវលេខ...........
ក្រុមទី........ ភូមិ................ ឃុំ-សង្កាត់........................ ស្រុក-ក្រុង-ខណ្ឌ........................
រាជធានី-ខេត្ត.................... លេខទូរសព្ទ............................................

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូង**..............................

*ជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

## ក-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឲ្យតុលាការចេញ

១-សម្រេចកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋាន.................................. លេខ...............
ឆ្នាំ............ ត្រង់បញ្ជីលេខ................ ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ.................. ចេញដោយមន្ត្រី
អត្រានុកូលដ្ឋាន.............................. ដូចខាងក្រោម៖

-ត្រង់ចំណុច.......................... ពី.......................... *ទៅ*..........................

-ត្រង់ចំណុច.......................... ពី.......................... *ទៅ*..........................

-............................................................................................។

២-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## ខ-អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ

ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា សំបុត្រអត្រានុកូលដ្ឋាន.................. របស់.................... ដែលចុះហត្ថលេខាដោយលោក/លោកស្រី...................... ជាមន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់............................ខាងលើនេះ មានកំហុសឆ្គងទិន្នន័យមួយចំនួនដែលមិនអាចប្រើប្រាស់បាន។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថា នឹងទទួលខុសត្រូវនូវរាល់ព្យសនកម្មនានា ដែលកើតឡើងពីការកែតម្រូវខាងលើនេះចំពោះមុខច្បាប់។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាពិនិត្យ និងកែតម្រូវទិន្នន័យក្នុងបញ្ជីអត្រានុកូលដ្ឋាន តាមការស្នើសុំរបស់ខ្ញុំបាទ/នាងខ្ញុំដោយអនុគ្រោះ។

សូម **ឯកឧត្តមប្រធានសាលាដំបូង** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.......................... ខែ.................. ឆ្នាំ............... ............ស័ក ព.ស. ២៥........

................ ថ្ងៃ................ ទី........ ខែ............ ឆ្នាំ២០..........

**ស្នាមមេដៃ / ហត្ថលេខា**

# ឧបសម្ព័ន្ធទី៥៖
# គំរូលិខិតបញ្ជាក់អត្តសញ្ញាណ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| **ខេត្ត / រាជធានី** | :………………… |
| **ស្រុក / ខណ្ឌ / ក្រុង** | :………………… |
| **ឃុំ / សង្កាត់** | :………………… |
| **លេខ** | :………………… |

4x6

**<u>លិខិតបញ្ជាក់</u>**

យើងមេឃុំ/ចៅសង្កាត់…………………ស្រុក/ខណ្ឌ/ក្រុង…………………ខេត្ត/រាជធានី…………

**សូមបញ្ជាក់ថា**

ឈ្មោះ……………………ជាអក្សរឡាតាំង……………………ថ្ងៃខែឆ្នាំកំណើត………………… ភេទ……
ឈ្មោះ……………………ជាអក្សរឡាតាំង……………………ថ្ងៃខែឆ្នាំកំណើត………………… ភេទ……
និងឈ្មោះ………………ជាអក្សរឡាតាំង……………………ថ្ងៃខែឆ្នាំកំណើត………………… ភេទ……
កើតនៅភូមិ……………………ឃុំ/សង្កាត់…………ស្រុក/ខណ្ឌ/ក្រុង…………………ខេត្ត/រាជធានី………
មានឪពុកឈ្មោះ……………………ថ្ងៃខែឆ្នាំកំណើត…………………មុខរបរ……………………………
និងម្តាយឈ្មោះ……………………ថ្ងៃខែឆ្នាំកំណើត…………………មុខរបរ……………………………
ដែលមានអាសយដ្ឋានអចិន្ត្រៃយ៍នៅភូមិ………………ឃុំ/សង្កាត់…………ស្រុក/ខណ្ឌ/ក្រុង………………
ខេត្ត/រាជធានី…………………… **ពិតជាមនុស្សតែម្នាក់ ប្រាកដមែន** ។
ហើយមូលហេតុដែលមានស្នាមកែកោលលុប ឬសរសេរខុសគ្នាដោយសារ……………………………………………។

យើងចេញលិខិតនេះជូនសាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ជាផ្លូវការតាមដែលអាចប្រើប្រាស់បាន។

ធ្វើនៅ………, ថ្ងៃទី………ខែ………ឆ្នាំ………
**មេឃុំចៅ/សង្កាត់** ……………………………
ហត្ថលេខា និងត្រា

# ឧបសម្ព័ន្ធទី៦៖
# របៀបកែតម្រូវទិន្នន័យ តាមសេចក្តីសម្រេច
# របស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
# ក្នុងឆ្នាំកន្លងផុត

បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវ

យោង...........លេខ...........ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........របស់.................។

ថ្ងៃទី..........ខែ...........ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងត្រា

# ឧបសម្ព័ន្ធទី៧៖

# របៀបរៀបចំពោលកម្មវិធីរបស់អនុគ្រាទុក្ខលង្កាន តាម

# សេចក្តីសម្រេចរបស់មន្ត្រីអនុគ្រាទុក្ខលង្កាន

# ថ្នាក់ជាតិ ក្នុងឆ្នាំកន្លងផុត

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

យោង...........លេខ...........ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........របស់.................។

ថ្ងៃទី..........ខែ...........ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងត្រា

# ឧបសម្ព័ន្ធទី៨៖

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសេចក្ដីសម្រេចរបស់តុលាការ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន
# តាមសេចក្តីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................ កើតថ្ងៃទី......... ខែ......... ឆ្នាំ..............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............ ផ្លូវ.............. ក្រុមទី........... ភូមិ.........................ឃុំ/សង្កាត់....................................... ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត........................ត្រូវជា(១) ................................។

## សូមគោរពជូន
## មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់.......................

**កម្មវត្ថុ** : សំណើសុំ ☐កែតម្រូវទិន្នន័យ ☐មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.....................តាមសេចក្តីសម្រេចរបស់តុលាការ។

**យោង** : (២)..............................................................................................................

..............................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក លោកស្រី មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់** មេត្តាជ្រាបថា សេចក្តីសម្រេចលេខ.........................ចុះថ្ងៃទី.........ខែ.........ឆ្នាំ..............របស់តុលាការ........................បានសម្រេច ☐កែតម្រូវទិន្នន័យ ☐មោឃភាពបញ្ជីអត្រានុកូលដ្ឋាន..............................របស់ឈ្មោះ..............................ភេទ......កើតថ្ងៃទី......ខែ...........ឆ្នាំ...........និងរបស់ឈ្មោះ.......................... ភេទ......កើតថ្ងៃទី......ខែ.........ឆ្នាំ...........ត្រង់បញ្ជីលេខ...........នៅក្នុងសៀវភៅលេខ.......ឆ្នាំ...........ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី..............................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់........................ ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត..............................។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពទិន្នន័យ បញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ....................ខែ..................ឆ្នាំ.........ស័ក

ធ្វើនៅ.....................ថ្ងៃទី.........ខែ.........

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

# ឧបសម្ព័ន្ធទី៩៖

# របៀបកែតម្រូវទិន្នន័យ បញ្ជីអត្រានុកូលដ្ឋាន

# តាមសេចក្តីសម្រេចរបស់តុលាការ

បញ្ជីអត្រានុកូលដ្ឋាននេះបានកែតម្រូវបាន

យោង...........លេខ...........ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........របស់.................។

ថ្ងៃទី..........ខែ...........ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងត្រា

# ឧបសម្ព័ន្ធទី១០៖
# របៀបគោរពភាពបញ្ជីរសូត្រានុកូលដ្ឋានតាម
# សេចក្តីសម្រេចរបស់តុលាការ

បញ្ជីអត្រានុកូលដ្ឋាននេះអស់សុពលភាព

យោង...........លេខ...........ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........របស់.................។

ថ្ងៃទី..........ខែ...........ឆ្នាំ.........

មន្ត្រីអត្រានុកូលដ្ឋាន

ហត្ថលេខានិងត្រា

# ឧបសម្ព័ន្ធទី១១៖

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជី អត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន

# តាមសេចក្តីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................ កើតថ្ងៃទី......... ខែ......... ឆ្នាំ.............. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ.............. ក្រុមទី........... ភូមិ........................ ឃុំ/សង្កាត់...................................... ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត........................ ត្រូវជា(១) ............................។

**សូមគោរពជូន**

**អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**.......................

**កម្មវត្ថុ** : សំណើសុំ □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.....................តាមសេចក្តីសម្រេចរបស់តុលាការ។

**យោង** : (២)..................................................................................................

..................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **លោក លោកស្រី អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា សេចក្តីសម្រេចលេខ........................ចុះថ្ងៃទី......... ខែ......... ឆ្នាំ............របស់តុលាការ........................បានសម្រេច □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន ... ................ របស់ឈ្មោះ..............................ភេទ......កើតថ្ងៃទី......ខែ...........ឆ្នាំ...........និងរបស់ឈ្មោះ... ........................ ភេទ......កើតថ្ងៃទី......ខែ...........ឆ្នាំ..................ត្រង់បញ្ជីលេខ............នៅក្នុងសៀវភៅលេខ.........ឆ្នាំ........... ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី...........................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់ ................... ក្រុង/ស្រុក/ខណ្ឌ.....................រាជធានី/ខេត្ត.....................។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ថ្ងៃ...................ខែ...............ឆ្នាំ........ស័ក ព.ស.២៥...

ធ្វើនៅ.................. ថ្ងៃទី......... ខែ........... ឆ្នាំ២០...

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

# ឧបសម្ព័ន្ធទី១២៖

# ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជី អត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចរបស់តុលាការ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំកែតម្រូវទិន្នន័យ និងមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្ដីសម្រេចរបស់តុលាការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ............................ កើតថ្ងៃទី........ ខែ........ ឆ្នាំ.............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ.............. ក្រុមទី........... ភូមិ.........................ឃុំ/សង្កាត់.................................... ក្រុង/ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត.........................ត្រូវជា⁽¹⁾ ............................។

**សូមគោរពជូន**

**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

**និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ**

**កម្មវត្ថុ** : សំណើសុំ □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.......................តាមសេចក្ដីសម្រេចរបស់តុលាការ។

**យោង** : ⁽²⁾ .......................................................................................................................................

.......................................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាជ្រាបថា សេចក្ដីសម្រេចលេខ.........................ចុះថ្ងៃទី......... ខែ......... ឆ្នាំ..............របស់តុលាការ ...........................បានសម្រេច □កែតម្រូវទិន្នន័យ □មោឃភាពបញ្ជីអត្រានុកូលដ្ឋាន.....................របស់ឈ្មោះ ..............................ភេទ.....កើតថ្ងៃទី.....ខែ...........ឆ្នាំ........ និងរបស់ឈ្មោះ...........................ភេទ.....កើតថ្ងៃទី.....ខែ........ឆ្នាំ..............ត្រង់បញ្ជីលេខ........នៅក្នុងសៀវភៅលេខ........ឆ្នាំ...........ដែលបានចុះហត្ថលេខាដោយលោក/លោកស្រី.................ជាមន្ត្រីអត្រានុកូលដ្ឋានឃុំ/សង្កាត់.....................ក្រុង/ស្រុក/ខណ្ឌ.....................រាជធានី/ខេត្ត.................។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ** មេត្តាធ្វើការកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ថ្ងៃ...................ខែ..................ឆ្នាំ........ស័ក ព.ស.២៥...

ធ្វើនៅ.................... ថ្ងៃទី........ ខែ........... ឆ្នាំ២០...

ស្នាមមេដៃសាមីខ្លួន/អាណាព្យាបាល/ញាតិ

លេខ: ................

បានឃើញ និងបញ្ជាក់ថាស្នាមមេដៃខាងស្ដាំនេះពិតស្នាមមេដៃ របស់ឈ្មោះ................................ ពិតប្រាកដមែន។

ថ្ងៃ...................ខែ..................ឆ្នាំ........ស័ក ព.ស.២៥...

ធ្វើនៅ.................... ថ្ងៃទី........ ខែ........... ឆ្នាំ២០...

**ប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន**